**អង្គការសហប្រជាជាតិ** A/HRC/56/49/Add.2

**មហាសន្និបាត**

ផ្សព្វផ្សាយ៖ ទូទៅ
ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៤

ភាសាដើម៖ អង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទី៥៦**
ថ្ងៃទី១៨ ខែមិថុនា ដល់ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤
របៀបវារៈទី៣
**ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស សិទ្ធពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ គ្រប់ទម្រង់ រួមទាំងសិទ្ធិទទួលបានការអភិវឌ្ឍន៍**

# ទស្សនកិច្ចនៅកម្ពុជា

# របាយការណ៍អ្នកជំនាញឯករាជ្យស្តីពីការការពារអំពើហិង្សា និង ការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ*

*សេចក្តីសង្ខេប*

ក្នុងរបាយការណ៍នេះ លោក Victor Madrigal-Borloz អ្នកជំនាញឯករាជ្យស្តីពីការការពារអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ បានផ្តល់ព័ត៌មានអំពីដំណើរទស្សនកិច្ចរបស់លោក មកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី១០ ដល់ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។ ផ្អែកតាមព័ត៌មានប្រមូលបាននៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលនៃដំណើរទស្សនកិច្ច អ្នកជំនាញឯករាជ្យបានវាយតម្លៃអំពីការអនុវត្តបទដ្ឋានសិទ្ធិមនុស្សជាតិ និងអន្តរជាតិដែលមានស្រាប់ សំដៅប្រយុទ្ធប្រឆាំងអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ព្រមទាំងបានបង្ហាញទិដ្ឋភាពដ៏ទូលំទូលាយអំពីស្ថានភាពសិទ្ធិមនុស្សរបស់ ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរយេនឌ័រ និងបុគ្គលដែលមានភេទចម្រុះជាច្រើនទៀតនៅកម្ពុជា។ អ្នកជំនាញបានលើកឡើងអំពីការអនុវត្តល្អៗ និងបញ្ហាប្រឈមដែលនៅសេសសល់ និងបានលើកអនុសាសន៍សំដៅពង្រឹងការការពារអំពើហិង្សានិងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

* សេចក្តីសង្ខេបរបាយការណ៍ បានចេញផ្សាយជាភាសាផ្លូវការទាំងអស់។ ដោយឡែក របាយការណ៍ ដែលបានដាក់ភ្ជាប់ជាមួយសេចក្តីសង្ខេបរបាយការណ៍ បានចេញផ្សាយជាភាសាដែលសរសេរក្នុងរបាយការណ៍តែប៉ុណ្ណោះ។

GE.24-06030 (E) 150424 160424

Please recycle

## ឧបសម្ព័ន្ធ

### របាយការណ៍នៃដំណើរទស្សនកិច្ចនៅកម្ពុជារបស់អ្នកជំនាញឯករាជ្យស្តីពីការការពារអំពើហិង្សា និងការរើសអើងដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ

### I. សេចក្តីផ្តើម

១. អនុលោមតាមសេចក្តីសម្រេចលេខ ៥០/១០ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស លោក Victor Madrigal-Borloz អ្នកជំនាញឯករាជ្យស្តីពីការការពារអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ បានមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជាចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ តបតាមការអញ្ជើញរបស់រាជរដ្ឋាភិបាល។ ដំណើរទស្សនកិច្ចនេះមានគោលបំណងវាយតម្លៃស្ថានភាពសិទ្ធិមនុស្សរបស់ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរយេនឌ័រ និងបុគ្គលដែលមានភេទចម្រុះផ្សេងទៀតនៅកម្ពុជា (អ្នកស្រឡាញ់ភេទដូចគ្នា) និងកត់សម្គាល់នូវការអនុវត្តល្អៗ និងចំណុចត្រូវកែលម្អ ក្នុងការអនុវត្តបទដ្ឋានសិទ្ធិមនុស្សជាតិ និងអន្តរជាតិ ដើម្បីលុបបំបាត់អំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

២. ក្នុងដំណើរទស្សនកិច្ចនេះ អ្នកជំនាញឯករាជ្យបានធ្វើទស្សនកិច្ចនៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តបាត់ដំបង លោកក៏បានជួបជាមួយតំណាងរដ្ឋាភិបាលជាច្រើនរូប ទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត។ លោកសូមថ្លែងអំណរគុណរាជរដ្ឋាភិបាលកម្ពុជាចំពោះការអញ្ជើញ កិច្ចសហប្រតិបត្តិការ និងបដិសណ្ឋារកិច្ចដ៏ល្អឥតខ្ចោះក្នុងអំឡុងដំណើរទស្សនកិច្ចនេះ។ លោកមានសេចក្តីសោមនស្ស ចំពោះការជជែកពិភាក្សាដោយបើកចំហ ដោយគោរព និងដោយស្មោះត្រង់ និងចំពោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលថានឹងយកចិត្តទុកដាក់ និងគិតគូរពីបញ្ហាសិទ្ធិមនុស្សក្នុងបរិបទនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រសម្រាប់ពេលអនាគត។

៣. អ្នកជំនាញឯករាជ្យក៏បានជួបជាមួយអ្នកការពារសិទ្ធិមនុស្ស និងអង្គការសង្គមស៊ីវិលជាច្រើន ដែលកំពុងបម្រើការក្នុងវិស័យនានា ដែលមានទំនាក់ទំនងនឹងការងារដែលអ្នកជំនាញកំពុងផ្តោតការយកចិត្តទុកដាក់ ហើយជារួម បានជួយសម្របសម្រួលទំនាក់ទំនងជាមួយអ្នកស្រឡាញ់ភេទដូចគ្នា ជាង ១០០នាក់ ដែលធ្លាប់ឆ្លងកាត់បទពិសោធន៍រងអំពើហិង្សា និងការរើសអើងក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ អ្នកជំនាញឯករាជ្យសូមបង្ហាញអំណរគុណយ៉ាងជ្រាលជ្រៅដល់សង្គមស៊ីវិល និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា នៅកម្ពុជា ចំពោះការបើកចិត្តទូលាយក្នុងការចែករំលែករឿងរ៉ាវ ក៏ដូចជាព័ត៌មាន និងការវិភាគនានា។

៤. អ្នកជំនាញឯករាជ្យ ក៏បានជួបក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ និងសមាជិកអង្គទូតនានាដែរ។ លោកសូមថ្លែងអំណរគុណអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា និងក្រុមការងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ ដែលបានគាំទ្រ និងជួយរៀបចំដំណើរទស្សនកិច្ច ក៏ដូចជាការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ចំពោះការគាំទ្រ និងកិច្ចសហការដ៏ល្អ។ ការបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមជូនអង្គការសហប្រជាជាតិ នឹងមានប្រយោជន៍បំផុត នៅពេលដែលគ្រប់អង្គភាពនៃក្រុម

គ្រួសារអង្គការសហប្រជាជាតិ ខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការចែករំលែកព័ត៌មាន និងសម្របសម្រួលកិច្ចការងារនានា។ អ្នកជំនាញឯករាជ្យជឿជាក់ថា ដោយសារតែការបំពេញការងារប្រកបដោយគោលការណ៍ របស់មន្ត្រីអង្គការសហប្រជាជាតិនៅកម្ពុជា ដំណើរទស្សនកិច្ចនេះជាគំរូនៃការអនុវត្តល្អមួយ ដែលអ្នកជំនាញអន្តរជាតិលើកទឹកចិត្តឱ្យអ្នកដទៃទៀតយកគំរូតាម។

## II. បរិបទ និងសាវតារ

៥. អ្នកជំនាញឯករាជ្យកត់សម្គាល់ថា ប្រវត្តិសាស្ត្រកម្ពុជាមានភាពស្មុគស្មាញ និងសម្បូរបែប ជាប្រទេសដែលគោរពខ្ជាប់ខ្ជួននូវប្រពៃណី តម្លៃ និងវិធីសាស្ត្រប្រកបដោយមហិច្ឆតាឆ្ពោះទៅរកអនាគតដ៏វែងឆ្ងាយ និងការចង់បានការទទួលស្គាល់លើសាកលលោក។ លោកជឿជាក់យ៉ាងមុតមាំថា កត្តាទាំងនេះរួមគ្នាធ្វើឱ្យកម្ពុជាអាចមានលទ្ធភាពឆ្លើយតប និងទប់ទល់ផលជះដែលកើតមានថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងសកលលោក ទាក់ទងនឹងការការពារអំពើហិង្សា និងការរើសអើង សមស្របនឹងតថភាពជាក់ស្តែង ដែលមានអាយុកាលស្មើនឹងមនុស្សជាតិ ៖ ភាពចម្រុះនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

៦. ប្រទេសកម្ពុជាបានឆ្លងកាត់កំណើនសេដ្ឋកិច្ច និងការផ្លាស់ប្តូរមុខមាត់សង្គមគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ប្រែក្លាយជា "ប្រទេសមួយដែលមានសេដ្ឋកិច្ចលូតលាស់លឿនបំផុតក្នុងពិភពលោក និងសម្រេចបានគួរឱ្យស្ងប់ស្ងែងនូវការកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យសូចនាករសង្គមកាន់តែល្អប្រសើរឡើង"[1]។ ក្រុមការងារទទួលបន្ទុកការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ បានកត់សម្គាល់កាលពីឆ្នាំ២០១៩ ថាកម្ពុជាបានកាត់បន្ថយអត្រាភាពក្រីក្រខ្លាំង និងមរណភាពមាតាបានពាក់កណ្តាល ដែលនេះធ្វើឱ្យជិតសម្រេចបាននូវគោលដៅជាសាកល នៃការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា និងវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការប្រយុទ្ធប្រឆាំងមេរោគអេដស៍/ជំងឺអេដស៍ ចាប់តាំងពីឆ្នាំ១៩៩០ រហូតមក[2]។

៧. កត្តាសំខាន់ៗចំនួនបួន រួមគ្នាបង្កើតជាបរិបទពិសេសដោយឡែកមួយសម្រាប់ដំណើរទស្សនកិច្ច ៖ អាណត្តិការងារស្របគ្នាជាមួយអ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ ដែលបង្អាក់កំណើនសេដ្ឋកិច្ច និងបង្កជាសម្ពាធតានតឹងដល់ស្ថាប័នរដ្ឋ និងមិនមែនរដ្ឋទាំងអស់ គោលដៅអភិវឌ្ឍន៍ប្រកបដោយមហិច្ឆតារបស់រដ្ឋាភិបាលកម្ពុជា និងការប្តេជ្ញាចិត្តចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការបោះឆ្នោតថ្នាក់មូលដ្ឋានដែលបានរៀបចំឡើងក្នុងឆ្នាំ២០២២ និងការបោះឆ្នោតជាតិក្នុងឆ្នាំ២០២៣ ដែលកំពុងខិតជិតចូលមកដល់ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ច។

៨. បុគ្គលដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះនៅកម្ពុជា បង្ហាញអត្តសញ្ញាណរបស់ពួកគេ ក្រោមរូបភាពជាច្រើន ក្នុងនោះរួមមាន ៖ ស្ត្រីស្រឡាញ់ស្ត្រី បុរស

[1] A/HRC/41/17 កថាខណ្ឌ ៦។

[2] ដូចខាងលើ។

ស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរយេនឌ័រពីបុរសទៅជាស្ត្រី អ្នកប្តូរយេនឌ័រពីស្ត្រីទៅជាបុរស ភេទទីបី អ្នកមិនកំណត់អត្តសញ្ញាណភេទខ្លួនឯង និងស៊ីម[3]។ ក្នុងចំណោមពាក្យទាំងនេះ មានតែពាក្យមួយចំនួនប៉ុណ្ណោះដែលត្រូវគ្នានឹងពាក្យកាត់ LGBT ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជុំវិញពិភពលោក និងជាពិសេសប៉ែកខាងជើងនៃពិភពលោក។ អត្តសញ្ញាណមួយចំនួនដែលប្រើនៅកម្ពុជា គឺផុតពីគោលគំនិតដ៏តឹងរ៉ឹង ទាក់ទងនឹងអត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ ឬនិន្នាការភេទ ហើយអាស្រ័យលើភាសាប្រើប្រាស់ គេមិនសូវ ឬញែកឱ្យដាច់រវាងពាក្យ "ភេទ" "យេនឌ័រ" "អត្តសញ្ញាណយេនឌ័រ" និង/ឬ "អត្តសញ្ញាណភេទ" នោះទេ។ អ្នកជំនាញឯករាជ្យផ្តល់យោបល់យ៉ាងមុតមាំថា ទស្សនៈយល់ឃើញ និងការកំណត់អត្តសញ្ញាណដោយសាមីខ្លួន ក្នុងចំណោមប្រជាជនកម្ពុជា និងសហគមន៍ ទាំងនេះអាចយកជាគោលការណ៍វិនិច្ឆ័យក្នុងការកំណត់វិធីសាស្ត្រនាពេលអនាគត ដើម្បីរកនិយមន័យនៃពាក្យ ប្រភេទ និងវាក្យស័ព្ទ។ ក្នុងន័យនេះ វិធីដែលច្បាប់ និងគោលនយោបាយកំណត់និយមន័យពាក្យ "អត្តសញ្ញាណ" មានឥទ្ធិពលយ៉ាងខ្លាំងចំពោះថាតើ និងក្នុងកម្រិតណាដែលសិទ្ធិមនុស្សដែលត្រូវបានការពារជាសកល ត្រូវបានទទួលស្គាល់ និងការពារក្រោមអំណាចច្បាប់ ហើយការប្រើពាក្យ ដូចជា "ភេទ" "យេនឌ័រ" "និន្នាការភេទ""អត្តសញ្ញាណយេនឌ័រ" និង "ការបង្ហាញយេនឌ័រ" អាចផ្តល់ឥទ្ធិពលពេញលេញ ឬការរឹតត្បិតហួសហេតុ ក្នុងការអនុវត្តសិទ្ធិមនុស្សជាសាកល។

៩. មានការយល់ខុសមួយដែលថា សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាមានតែមួយក្រុមតូច និង/ឬក្រុមបុគ្គលដែលមានសិទ្ធិពិសេស ហើយក៏កាន់តែនាំឱ្យមានការយល់ឃើញដូច្នេះ តាមរយៈរូបភាពរបស់តារាល្បីៗនៅតាមប្រព័ន្ធផ្សព្វផ្សាយ និងបេក្ខនារីប្តូរយេនឌ័រដែលទួលបានជ័យលាភីក្នុងកម្មវិធីប្រកួតបវរកញ្ញា។ នៅកម្ពុជា នៅពុំមានទិន្នន័យដែលស្ថាប័នរដ្ឋដឹកនាំប្រមូលនោះឡើយ ទោះយ៉ាងនេះក្តី តាមការសង្កេតមើល យើងឃើញថាមនុស្សរាប់សែននាក់មាននិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រចម្រុះ។ អ្នកជំនាញឯករាជ្យបានជួបនិស្សិតស្រឡាញ់ភេទដូចគ្នាដែលបញ្ចប់ការសិក្សាថ្នាក់សាកលវិទ្យាល័យ កសិករ សិល្បករ មន្ត្រីនគរបាល មន្ត្រីកិច្ចសន្យាក្នុងជួររដ្ឋាភិបាល និងអ្នកការពារសិទ្ធិមនុស្ស បុគ្គលដែលមានសាវតារជាតិពន្ធុផ្សេងៗគ្នា រួមទាំងជនជាតិដើមភាគតិច អ្នកនៅទីក្រុង និងអ្នកជនបទ យុវជនអាយុក្រោម ១៨ឆ្នាំ និងមនុស្សចាស់អាយុរហូត ៧២ឆ្នាំ អ្នកដែលប្រកាសថាខ្លួនមានជីវភាពធូរធារ និងអ្នកទីទាល់ក្រ។ នេះបង្ហាញថាមានអ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននៅកម្ពុជា ដែលចំណុចនេះ មានភាពពាក់ព័ន្ធយ៉ាងខ្លាំងសម្រាប់ការបង្កើតគោលនយោបាយរដ្ឋ ដើម្បីឆ្លើយតបគោលការណ៍មិនទុកនរណាម្នាក់ចោល និងប្រកាន់ខ្ជាប់កាតព្វកិច្ចសិទ្ធិមនុស្សដែលរដ្ឋត្រូវគោរពតាមឱ្យបានខ្ជាប់ខ្ជួន។

១០. អ្នកជំនាញឯករាជ្យមិនបានទទួលរបាយការណ៍ ពីអំពើហិង្សាផ្លូវកាយទ្រង់ទ្រាយធំជាប្រព័ន្ធ ឬជាក់ស្តែងលើបុគ្គលណាម្នាក់ ផ្អែកលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ខ្លួននៅកម្ពុជានោះទេ។ យោងតាមតួអង្គរដ្ឋ និងមិនមែនរដ្ឋជាច្រើន ករណីនេះអាចដោយសារតែក្នុងសង្គមកម្ពុជាមានកម្រិតការអត់ឱនខ្ពស់ និងដោយសារទំនៀមប្រពៃណីសាសនា និង

[3] សូមមើល ឧទាហរណ៍ https://www.undp.org/sites/g/files/zskgke326/files/migration/asia_pacific_rbap/rbap-hhd-2014-blia- cambodia-country-report_0.pdf.

ជំហរផ្លូវការរបស់រដ្ឋាភិបាល។ ស្ទើរតែគ្រប់ករណីទាំងអស់ មន្ត្រីរដ្ឋាភិបាលដែលអ្នកកាន់អាណត្តិបានជួបប្រាស្រ័យទាក់ទង បានទទួលស្គាល់ពីដើមដំបូងថា ភាពចម្រុះនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ជាចរិតលក្ខណៈដែលមិនអាចកាត់ផ្តាច់បានរបស់មនុស្សជាតិ ហើយប្រជាពលរដ្ឋខ្មែរទាំងអស់ រួមទាំងសមាជិកនៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា គឺជាសមាជិកដ៏មានតម្លៃរបស់សង្គម ដែលគួរទទួលបានសេរីភាព និងសមភាព។ អ្នកជំនាញឯករាជ្យបានកត់សម្គាល់ដោយពេញចិត្តថា មានការប្រារព្ធទិវាមោទនភាពនៅកម្ពុជា តាំងពីឆ្នាំ២០០៩ ដែលធ្វើឱ្យសាធារណជនកាន់តែបានឃើញ និងមានការចូលរួមកាន់តែច្រើន[4]។ ការគោរព និងការគាំទ្រក្នុងកម្រិតខ្ពស់បែបនេះពីរដ្ឋាភិបាល មានឥទ្ធិពលវិជ្ជមានលើភាពអត់ឱនចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងនាមជាសមាជិកក្នុងសង្គម ដែលគួរទទួលបានកិច្ចការពារ និងសិទ្ធិស្មើគ្នា។ ម្យ៉ាងវិញទៀត ការអនុម័តក្របខ័ណ្ឌច្បាប់ និងគោលនយោបាយការពារអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ នឹងមានផលជះជាវិជ្ជមានលើការទទួលយកអ្នកស្រឡាញ់ភេទដូចគ្នាក្នុងសង្គម ចូលរួមលើកកម្ពស់គុណតម្លៃឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់គ្នា ទទួលបានការគោរពសិទ្ធិមនុស្សពេញលេញ។

## III. ក្របខណ្ឌច្បាប់ ស្ថាប័ន និងគោលនយោបាយសាធារណៈ

### ក. កាតព្វកិច្ចអន្តរជាតិ និងសុខដុមរមនីយកម្មនៃច្បាប់ជាតិ

១១. កម្ពុជាជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សស្នូលចំនួនប្រាំបួន និងពិធីសារបន្ថែមចំនួនបួន រួមទាំងពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ កម្ពុជាក៏បានបង្កើតក្របខ័ណ្ឌស្ថាប័នរឹងមាំសម្រាប់ការអនុវត្តកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន។ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប និងពិធីសារបន្ថែមនៃ អនុសញ្ញាប្រឆាំងទារុណកម្ម។ ប៉ុន្តែ កម្ពុជាមិនទាន់ចុះហត្ថលេខាទទួលស្គាល់ពិធីសារបន្ថែមទីពីរ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សំដៅលុបចោលទោសប្រហារជីវិត ឬនីតិវិធីទំនាក់ទំនងអន្តររដ្ឋ ដូចមានចែងក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំនៅឡើយ។ កម្ពុជាក៏នៅមិនទាន់ផ្តល់សច្ចាប័នលើពិធីសារបន្ថែមទី១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពិធីសារបន្ថែមនៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងនីតិវិធីទំនាក់ទំនង និងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដែលប្រសិនបើចុះសច្ចាប័ន កម្ពុជានឹងទទួលយកនីតិវិធីបណ្តឹងបុគ្គលដូចមានចែងក្នុងសន្ធិសញ្ញាទាំងនេះ[5]។

១២. ក្នុងអំឡុងការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ លើកទីបី ក្នុងឆ្នាំ២០១៩ កម្ពុជាទទួលយកអនុសាសន៍ចំនួន ៩ ទាក់ទងជាក់លាក់នឹងការការពារសិទ្ធិ អ្នកស្រឡាញ់

[4] A/HRC/42/60/Add.1, កថាខណ្ឌ ៥៦។

[5] សូមមើល គេហទំព័រ https://tbinternet.ohchr.org/_layouts/15/TreatyBodyExternal/Treaty.aspx។

ភេទដូចគ្នា និងអន្តរភេទ[6]។ អនុសាសន៍ទាំងនេះផ្តោតលើកំណែទម្រង់ច្បាប់ និងគោលនយោបាយសំខាន់ៗចំនួនបី៖ (ក) វិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុញ្ញាតសមភាពនៃអាពាហ៍ពិពាហ៍ស្របច្បាប់សម្រាប់ដៃគូភេទដូចគ្នា (ខ) អនុម័តច្បាប់ និងគោលនយោបាយ ធានាការមិនរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណ និងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និង (គ) អនុម័តច្បាប់អនុញ្ញាតឱ្យមានការទទួលស្គាល់យេនឌ័រស្របច្បាប់សម្រាប់អ្នកប្តូរយេនឌ័រ។ រាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្តអនុសាសន៍ទាំងនេះ មុនវដ្តនៃការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ ក្នុងឆ្នាំ២០២៣។ ប៉ុន្តែ រហូតមកទល់ពេលនេះ ពុំទាន់មានអនុសាសន៍ណាមួយត្រូវបានអនុវត្តនៅឡើយ។

១៣. អ្នកជំនាញឯករាជ្យស្វាគមន៍ ចំពោះការចូលរួមរបស់កម្ពុជាជាមួយនឹងយន្តការសិទ្ធិមនុស្សជាច្រើន រួមទាំងនីតិវិធីពិសេស ក៏ដូចជារបាយការណ៍ដាក់ជូនស្ថាប័នសន្ធិសញ្ញា និងការចូលរួមយន្តការពិនិត្យឡើងវិញជាសកលតាមកាលកំណត់។ មិនខុសពីអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នកជំនាញឯករាជ្យក៏លើកទឹកចិត្តឱ្យរាជរដ្ឋាភិបាល បន្តរៀបចំផែនការអនុវត្ត សម្រាប់យន្តការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ និងចូលរួមក្នុងកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំរវាង រាជរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូសហប្រតិបត្តិការនានា[7]។

## ខ. ក្របខណ្ឌច្បាប់

១៤. កម្មសិទ្ធិសាធារណៈចំពោះគោលការណ៍នៃការគោរពគ្នានៅកម្ពុជា ត្រូវបានពង្រឹងតាមរយៈបទដ្ឋានរដ្ឋធម្មនុញ្ញ និងច្បាប់។ ខុសពីបណ្តាប្រទេសមួយចំនួនក្នុងតំបន់ កម្ពុជាមិនមានច្បាប់ដាក់ទោសទណ្ឌដោយបើកចំហចំពោះនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះទេ។ ចំណុចគួរកត់សម្គាល់ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនតិចក្នុងពិភពលោក ដែលពុំធ្លាប់បានចាត់ទុក និន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ជាបទល្មើសព្រហ្មទណ្ឌ។

១៥. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថា កម្ពុជាទទួលស្គាល់ និងគោរពច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ កម្ពុជាធានានូវសមភាពចំពោះមុខច្បាប់សម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ដោយគ្មានការរើសអើង "ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ទំនោរនយោបាយ ដើមកំណើត ឋានៈសង្គម ទ្រព្យសម្បត្តិ ឬឋានៈផ្សេងទៀត"។ ទោះបីជានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ស្ថិតក្រោម "ឋានៈផ្សេងទៀត" ក៏ដោយ កង្វះការការពារជាក់លាក់ចំពោះការរើសអើងផ្អែកលើមូលដ្ឋានទាំងនេះក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់កម្ពុជា បង្កើតចន្លោះប្រហោងក្នុងកិច្ចការពារ ដែលរារាំងការកំណត់ និងរាយការណ៍អំពីស្ថានភាពនៃការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ធានាការទទួលខុសត្រូវ និងផ្តល់សំណងដល់ជនរងគ្រោះ។

១៦. ប្រទេសកម្ពុជាពុំមានច្បាប់ការពារប្រឆាំងនឹងការរើសអើង ផ្អែកលើនិន្នាការភេទ និង

[6] A/HRC/41/17/Add.1, កថាខណ្ឌ ២ ; A/HRC/45/51 និង A/HRC/41/17 កថាខណ្ឌ ១១០.៤៥–១១០.៤៧ និង ១១០.៥០–១១០.៥៥។

[7] A/HRC/45/51 កថាខណ្ឌ ៨៣។

អត្តសញ្ញាណយេនឌ័រ។ គណៈកម្មាធិការសិទ្ធិមនុស្ស[8] និងអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា[9] បានផ្តល់អនុសាសន៍ឱ្យអនុម័តច្បាប់ហាមប្រាមចំពោះការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ ក្នុងឆ្នាំ២០១៩ រដ្ឋាភិបាលបានទទួលយកអនុសាសន៍មួយចំនួន ក្នុងអំឡុង ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ ថានឹងអនុម័តច្បាប់នេះក្នុងឆ្នាំ ២០២៣។

១៧. មាត្រា ១០ នៃក្រមរដ្ឋប្បវេណីការពារសិទ្ធិអត្តសញ្ញាណ សេចក្តីថ្លៃថ្នូរ និងឯកជនភាព។ ប៉ុន្តែ ប្រទេសនេះមិនមានច្បាប់ណាមួយអនុញ្ញាតឱ្យអ្នកប្តូរយេនឌ័រ និងអ្នកមានយេនឌ័រចម្រុះ អាចមានអត្តសញ្ញាណយេនឌ័រកំណត់ដោយសាមីខ្លួន ហើយទទួលស្គាល់ស្របច្បាប់នោះទេ។ រដ្ឋាភិបាលទទួលយកអនុសាសន៍ ថានឹងមានច្បាប់ស្តីពីការទទួលស្គាល់យេនឌ័រស្របច្បាប់ ក្នុងអំឡុងពេលនៃការពិនិត្យឡើងវិញជាសកលតាមកាលកំណត់លើកទីបីរបស់ខ្លួន។ អ្នកជំនាញឯករាជ្យកត់សម្គាល់ថា ក្របខណ្ឌច្បាប់បច្ចុប្បន្នមិនមានបទប្បញ្ញត្តិហាមឃាត់ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់នោះទេ។ ជាងនេះទៀត ការអនុម័តច្បាប់ផ្តល់ការទទួលស្គាល់តាមផ្លូវច្បាប់ ផ្អែកលើមូលដ្ឋាននៃការកំណត់អត្តសញ្ញាណដោយសាមីខ្លួន នឹងជាសកម្មភាពដែលធ្វើឡើងទាន់ពេលវេលា ដោយសារប្រទេសកម្ពុជាកំពុងអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ២០១៧-ឆ្នាំ២០២៦ ក្នុងគោលបំណងកសាងប្រព័ន្ធអត្រានុកូលដ្ឋានជាសាកល អចិន្ត្រៃយ៍ និងទំនើបទាន់សម័យ ក៏ដូចជាការបង្កើតប្រព័ន្ធរួមនៃអត្តសញ្ញាណកម្មប្រជាជន[10]។

១៨. ការទទួលស្គាល់តាមផ្លូវច្បាប់នៃអត្តសញ្ញាណយេនឌ័រ ដែលកំណត់ដោយសាមីខ្លួននឹងក្លាយជាជំហានដ៏សំខាន់មួយសំដៅដល់បរិយាប័ន្នសង្គមនៃអ្នកប្តូរយេនឌ័រ និងអ្នកមានយេនឌ័រចម្រុះ ដែលប្រឈមឧបសគ្គធ្ងន់ធ្ងរដោយសារតែភាពលម្អៀង មិនស៊ីសង្វាក់រវាងការកំណត់យេនឌ័រលើឯកសារអត្តសញ្ញាណ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ដោយមានផលប៉ះពាល់អវិជ្ជមានជាក់ស្តែងទាក់ទងនឹងលទ្ធភាពទទួលបានការងារធ្វើ ការថែទាំសុខភាព និងការអប់រំ ក៏ដូចជាសុខភាពផ្លូវចិត្ត លទ្ធភាពធ្វើដំណើរ និងសិទ្ធិគ្រួសាររបស់ពួកគេ ក្នុងចំណោមសិទ្ធិផ្សេងទៀត។

១៩. កម្ពុជាទទួលយកអនុសាសន៍ ដើម្បីឱ្យមានការទទួលស្គាល់តាមផ្លូវច្បាប់នូវអាពាហ៍ពិពាហ៍ភេទដូចគ្នា ក្នុងអំឡុងការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ លើកទីបីរបស់ខ្លួន។ ទោះជាបែបនេះក្តី ការរៀបការភេទដូចគ្នានៅតែត្រូវបានហាមឃាត់ក្នុងច្បាប់កម្ពុជា យោងតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ (ដែលកំណត់ការរៀបអាពាហ៍ពិពាហ៍ "រវាងប្តី និងប្រពន្ធ") ក្រមរដ្ឋប្បវេណី (គន្ថីទី៧) និងមាត្រា ៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ (ឆ្នាំ១៩៨៩)។ ក្នុងឆ្នាំ២០២០ មានខេត្តចំនួន ១៥ ក្នុងចំណោមខេត្តទាំង ២៤ នៅកម្ពុជា បានអនុម័តនីតិវិធី "សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ" សំដៅដល់ "កិច្ចសន្យារដ្ឋប្បវេណីរវាងពលរដ្ឋពីររូបស្ម័គ្រចិត្តរួមរស់ជាមួយគ្នា និងទទួលខុសត្រូវរួមក្នុងការមើលថែគ្រួសារ កូន និង

8 CCPR/C/KHM/CO/2, កថាខណ្ឌ ៩។

9 A/HRC/42/60 កថាខណ្ឌ ៣៣; និង A/HRC/42/60/Add.1, កថាខណ្ឌ ៦១។

10 សូមមើល https://getinthepicture.org/resource/cambodia-national-strategic-plan-identification-2017-2026.

បែងចែកទ្រព្យរួមគ្នា ដូចប្តីប្រពន្ធស្របច្បាប់"[11]។

២០. ទោះបីការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នា ជារឿងខុសច្បាប់ គូស្នេហ៍ភេទដូចគ្នា ជាធម្មតា រៀបអាពាហ៍ពិពាហ៍ទៅតាមប្រពៃណីប្រទេសកម្ពុជា[12] បើទោះជាទំនាក់ទំនងជាដៃគូបែបនេះពុំមានការទទួលស្គាល់តាមផ្លូវច្បាប់ក៏ដោយ។ គូស្វាមីភរិយាភេទដូចគ្នា ជួនកាលទទួលបានការទទួលស្គាល់តាមផ្លូវច្បាប់ខ្លះដែរ ក្នុងទម្រង់ជាសៀវភៅគ្រួសារដែលផ្តល់ដោយអាជ្ញាធរមូលដ្ឋាន ចាត់ទុកពួកគេជាប្តីប្រពន្ធ ឬជាបងប្អូនបង្កើត[13]។ ប៉ុន្តែ ការអនុវត្តបែបនេះ នៅពុំទាន់បានខ្ជាប់ខ្ជួន និងពុំបានផ្តល់សិទ្ធិ និងកាតព្វកិច្ចពេញលេញ ដូចមានភ្ជាប់ជាមួយនឹងអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ។ ការពុំមានលទ្ធភាពរៀបអាពាហ៍ពិពាហ៍ស្របច្បាប់រារាំងគូស្នេហ៍ភេទដូចគ្នា ក្នុងការទទួលបានសិទ្ធិ និងសិទ្ធិពិសេសជាច្រើនដែលជាផ្លែផ្កានៃអាពាហ៍ពិពាហ៍ ដូចជា កម្មសិទ្ធិទ្រព្យសម្បត្តិរួម ការឃុំគ្រងកូន ពន្ធដារ មរតក និងការការពារពីការរំលោភបំពានក្នុងគ្រួសារ[14]។ លើសពីនេះ អ្នកស្រឡាញ់ភេទដូចគ្នាមិនមានសិទ្ធិសុំកូនពេញលេញ និងស្មើភាពគ្នានោះទេ។

២១. តម្លៃសង្គម គឺស្ថិតក្នុងក្របខ័ណ្ឌច្បាប់បែបនេះ។ អង្គការសង្គមស៊ីវិលបានពន្យល់ថា "ស្ថាប័នអាពាហ៍ពិពាហ៍មានតម្លៃពិសេសខ្លាំងនៅកម្ពុជា ហើយការមិនរាប់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកមានយេនឌ័រចម្រុះ ក្នុងទំនៀមទម្លាប់អាពាហ៍ពិពាហ៍ គឺជាការផាត់ពួកគេចេញពីមូលដ្ឋានគ្រឹះមួយក្នុងសង្គមកម្ពុជា"[15]។ គ្រួសារត្រូវបានគេមើលឃើញថាជាសមាសជាតុសំខាន់មួយក្នុងការស្វែងរកសុភមង្គល ហើយឪពុកម្តាយភាគច្រើនយល់ថាកូនៗគឺជាផ្នែកមួយនៃខ្លួនពួកគាត់ និងតែងតែចង់ឱ្យកូនៗរបស់ពួកគាត់មានជីវភាពស្ថិតស្ថេរ ស្ងប់ស្ងាត់ និងរីករាយក្នុងជីវិត ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ៖ វិជ្ជាជីវៈ ផ្ទាល់ខ្លួន និងសង្គម។ ជាលទ្ធផល កូនៗដើរតួនាទីសំខាន់ក្នុងការគាំទ្រផ្នែកផ្លូវចិត្ត និងគាំទ្រជាក់ស្តែងដល់ឪពុកម្តាយពេលពួកគាត់កាន់តែចាស់ទៅ។ ដោយសារតែការទទួលស្គាល់តាមផ្លូវច្បាប់ ចំពោះអាពាហ៍ពិពាហ៍ថាជាមូលដ្ឋានគ្រឹះនៃគ្រួសារ ត្រូវបានផ្តល់តម្លៃយ៉ាងជ្រាលជ្រៅ និងជាលក្ខខណ្ឌតម្រូវក្នុងការទទួលបានសិទ្ធិដ៏ច្រើនផ្សេងទៀត ដូច្នេះនេះអាចជាសម្ពាធដ៏ធ្ងន់ធ្ងរមួយដែលធ្វើឱ្យពួកគេត្រូវរៀបការជាមួយនឹងអ្នកមានភេទផ្ទុយ ដើម្បីឱ្យអាពាហ៍ពិពាហ៍នោះត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ គួបផ្សំនឹងការខ្វះចំណេះដឹងអំពីភាពចម្រុះនៃភេទ និងយេនឌ័រ ដែលនាំឱ្យគ្រួសារ និងសហគមន៍មានអារម្មណ៍អាម៉ាស់។

២២. មាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌ កំណត់ជាទោសព្រហ្មទណ្ឌចំពោះអំពើញុះញង់ឱ្យប្រព្រឹត្តការរើសអើង ការគុំកួន ឬហិង្សាចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយ ដោយមូលហេតុ ជាតិពន្ធុ សញ្ជាតិ ពូជសាសន៍ ឬសាសនា។ ប្រទេសកម្ពុជាមិនមានច្បាប់ណាមួយដាក់

---

[11] Lucas Ramón Mendos និងអ្នកផ្សេងទៀត *State-Sponsored Homophobia 2020: Global Legislation Overview Update* (Geneva, International Lesbian, Gay, Bisexual, Trans and Intersex Association, 2020), ទំព័រ ២៨៥។

[12] A/HRC/41/17 កថាខណ្ឌ ៨២។

[13] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងស្ថាប័នផ្សេងទៀត របាយការណ៍រួមដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សសម្រាប់ការពិនិត្យជាសាកលតាមកាលកំណត់ លើកទី ៣ នៅកម្ពុជា ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ កថាខណ្ឌ ១៣ អាចមើលបានតាមរយៈគេហទំព័រ https://ilga.org/wp-content/uploads/2024/03/stakeholdersreport_CAMBODIA_UPR32.pdf។

[14] A/HRC/42/60/Add.1, កថាខណ្ឌ ៥៧។

[15] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងស្ថាប័នផ្សេងទៀត របាយការណ៍រួមដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស កថាខណ្ឌ ១៣។

ទណ្ឌកម្មបទល្មើសស្អប់ខ្ពើម និងពាក្យសំដីពោរពេញដោយភាពស្អប់ខ្ពើមញុះញង់ឱ្យមានការរើសអើង ឬអំពើហិង្សា ផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនោះទេ។ ច្បាប់ប្រភេទនេះនឹងជាជំហានដ៏សំខាន់មួយ ធានាការពារអ្នកស្រឡាញ់ភេទដូចគ្នាពីអំពើហិង្សាដោយពាក្យសម្តី និងលើរូបរាងកាយ។

## គ. ក្របខណ្ឌស្ថាប័ន និងគោលនយោបាយ

២៣. ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជាស្ថាប័នសំខាន់ៗនៅកម្ពុជា ទទួលខុសត្រូវចំពោះគោលនយោបាយបរិយាប័ន្ន និងមិនរើសអើងនៅកម្ពុជា ជាពិសេសទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

២៤. ក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២ រាជរដ្ឋាភិបាលបានចេញផ្សាយសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស និងរៀបចំកិច្ចពិគ្រោះយោបល់យ៉ាងទូលំទូលាយ ក្រោមការរៀបចំរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដោយសហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្នុងគោលបំណងបង្កើតស្ថាប័នជាតិសិទ្ធិមនុស្សឯករាជ្យមួយ ស្របតាមគោលការណ៍ស្តីពីឋានៈនៃស្ថាប័នជាតិដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស (គោលការណ៍ទីក្រុងប៉ារីស)។ បន្ទាប់ពីដំណើរការវិភាគបច្ចេកទេសលើសេចក្តីព្រាងច្បាប់យ៉ាងទូលំទូលាយ និងការផ្ទៀងផ្ទាត់ជាមួយការអនុវត្តល្អៗក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក សេចក្តីព្រាងចុងក្រោយត្រូវបានរំពឹងថានឹងដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីពិចារណាក្នុងពេលឆាប់ៗនេះ។ អ្នកជំនាញឯករាជ្យវាយតម្លៃខ្ពស់ចំពោះដំណើរការនេះ និងចាត់ទុកថាការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្សស្របតាមគោលការណ៍ទីក្រុងប៉ារីសនឹងជាជំហានដ៏សំខាន់មួយសំដៅការពារអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

២៥. ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩-២០២៣) រួមបញ្ចូល ស្ត្រីស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ភេទទាំងពីរ និងស្ត្រីប្តូរយេនឌ័រ ក្នុងចំណោម "ស្ត្រីដែលកាន់តែរងការប្រឈម" នឹងអំពើហិង្សា។ ផែនការសកម្មភាពបញ្ជាក់យ៉ាងត្រឹមត្រូវថា "ស្ត្រីដែលរងការមាក់ងាយ និងត្រូវបានគេមិនយកចិត្តទុកដាក់ ឬមិនអើពើក្នុងសហគមន៍ ឬសង្គម ស្ថិតក្នុងស្ថានភាពងាយរងគ្រោះខ្លាំង ដែលកាន់តែងាយប្រឈមនឹងការរំលោភសិទ្ធិមនុស្ស ក៏ដូចជា អំពើហិង្សា" និងចាត់ទុកនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ជាកត្តាហានិភ័យ[16]។ នេះជាជំហានគួរឱ្យស្វាគមន៍ ដែលបង្ហាញការប្តេជ្ញាចិត្តដើម្បីបញ្ជ្រាបយេនឌ័ររបស់រដ្ឋាភិបាល ស្របតាមរបៀបវារៈស្តីពីការទប់ស្កាត់អំពើហិង្សាប្រកបដោយចីរភាព ដូចមានចែងក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ទោះជាយ៉ាងនេះក្តី ការអនុវត្តផែនការសកម្មភាពត្រូវបានចាត់ទុកថាជាចំណុចដែលគួរកែលម្អបន្ថែម។

២៦. គោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-ឆ្នាំ២០៣០ រួមបញ្ចូលអនុសាសន៍ដាក់បញ្ចូលការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយនៅតាមសាលារៀន និងមហាវិទ្យាល័យ ព្រមទាំងលើក

16 សូមមើលគេហទំព័រ https://cambodia.unfpa.org/sites/default/files/pub-pdf/nap_2019-2023_english_final.pdf, កថាខណ្ឌ ១.២.៤។

កម្ពស់ការប្រើប្រាស់ស្រោមអនាម័យ ដើម្បីឱ្យការរួមភេទក្នុងចំណោមយុវជនប្រកបដោយសុវត្ថិភាព[17]។ អាស្រ័យហេតុនេះ ក្នុងឆ្នាំ២០១៦ ទោះបីជាគោលនយោបាយនេះមិនបញ្ជាក់ជាក់លាក់អំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក៏ដោយ[18] ក៏ការអប់រំសុខភាពត្រូវបានដាក់បញ្ចូលជាមុខវិជ្ជានៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត។ ក្នុងខែមិថុនា ឆ្នាំ២០១៧ ក្រសួងអប់រំ យុវជន និងកីឡា ក្រោមកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល បានដាក់ចេញនូវកម្មវិធីសិក្សា "បំណិនជីវិតថ្មី" រួមមាន និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ការអប់រំផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រ[19]។ មុខវិជ្ជាថ្មីនេះគ្រោងបញ្ចូលជាផ្នែកមួយក្នុងកម្មវិធីសិក្សាក្នុងឆ្នាំ២០២៣ ក្រោយពីបានពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល និងមូលនិធិប្រជាជនអង្គការសហប្រជាជាតិ[20]។ ក្រសួងបានជូនដំណឹងដល់អ្នកជំនាញឯករាជ្យថា មេរៀន និងសៀវភៅសិក្សាគោលជាច្រើនត្រូវបានធ្វើបច្ចុប្បន្នភាពរួចរាល់ហើយ ដើម្បីរួមបញ្ចូលកម្មវិធីថ្មីនេះ។

២៧. អ្នកជំនាញឯករាជ្យគូសបញ្ជាក់អំពីសារសំខាន់ថា សេចក្តីថ្លែងការណ៍ធ្វើឡើងដោយអ្នកនយោបាយ នឹងជាការធានានូវការគោរពសិទ្ធិមនុស្សរបស់បុគ្គលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះនៅកម្ពុជា។ ក្នុងឆ្នាំ២០១៥ ក្រសួងព័ត៌មានបានចេញសេចក្តីថ្លែងការណ៍មួយអំពាវនាវឱ្យប្រព័ន្ធផ្សព្វផ្សាយ បញ្ឈប់ការចំអកឡកឡឺយដល់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា[21]។ ក្នុងឆ្នាំ២០២០ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានអំពាវនាវដល់ក្រុមគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា និងសង្គមកម្ពុជា ជារួម កុំឱ្យមានការរើសអើង ប្រព្រឹត្តអំពើហិង្សា និងគាបសង្កត់ផ្លូវចិត្ត ដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ[22]។ ទាំងនេះគឺជាគំរូល្អ នៃការបង្ហាញឆន្ទៈនយោបាយដែលពោរពេញដោយការគោរព និងទទួលស្គាល់ ហើយអ្នកជំនាញឯករាជ្យលើកទឹកចិត្តឱ្យអ្នកនយោបាយ និងអាជ្ញាធរវាយតម្លៃដោយប្រុងប្រយ័ត្នលើទម្ងន់នៃសេចក្តីថ្លែងការណ៍របស់ខ្លួន និងផលប៉ះពាល់នៃសេចក្តីថ្លែងការណ៍ទាំងនេះមុនពេលចេញផ្សាយ។ ជាពិសេស អ្នកជំនាញឯករាជ្យសង្កេតឃើញថា ក្នុងករណីខ្លះហាក់នៅខ្វះភាពស៊ីសង្វាក់រវាងសេចក្តីថ្លែងការណ៍ធ្វើឡើងក្នុង យន្តការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ និងសេចក្តីថ្លែងការណ៍នយោបាយដែលបានធ្វើឡើងក្នុងប្រទេស[23]។

## ឃ. ទិន្នន័យ

២៨. ដើម្បីដោះស្រាយរាល់ករណីនៃអំពើហិង្សា និងការរើសអើង ស្ថាប័នរដ្ឋមានតួនាទីសំខាន់ខ្លាំងណាស់។ មិនថាយើងកំពុងពិភាក្សាអំពីករណីនៃការស្វែងរកយុត្តិធម៌ ឬសុខភាពសាធារណៈ ឬ សេវាសង្គម គ្រប់ស្ថាប័នត្រូវពឹងអាស្រ័យលើអត្ថិភាពនៃគោលនយោបាយ

[17] សូមមើលគេហទំព័រ https://cambodia.unfpa.org/sites/default/files/pub-pdf/NPP_English_Final.pdf, កថាខណ្ឌ ២៥។

[18] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងស្ថាប័នផ្សេងទៀត របាយការណ៍រួមដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស កថាខណ្ឌ ៤៩។

[19] A/HRC/38/43 កថាខណ្ឌ ៧៤; និង A/HRC/42/60/Add.1 កថាខណ្ឌ ៥៦។

[20] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងស្ថាប័នផ្សេងទៀត របាយការណ៍រួមដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស កថាខណ្ឌ ៥០។

[21] ដូចខាងលើ កថាខណ្ឌ ២២។

[22] Pech Sotheary, "សេចក្តីអំពាវនាវឱ្យកាត់បន្ថយការរើសអើងចំពោះសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា" *សារព័ត៌មានខ្មែរថៃមស៍* ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០។

[23] សូមមើលគេហទំព័រ https://fb.watch/lmwYYfqGrT/?mibextid=Nif5oz (ជាភាសាខ្មែរ)។

សាធារណៈក្នុងគោលដៅទទួលស្គាល់នូវអត្តិភាព និងបញ្ហាប្រឈមជាក់លាក់ដែលអ្នកស្រឡាញ់ភេទដូចគ្នាកំពុងជួបប្រទះ។ គោលនយោបាយសាធារណៈបែបនេះ នឹងជាជំហានបន្ទាប់សម្រាប់រដ្ឋាភិបាលកម្ពុជា ដោយសារហេតុផលជាច្រើនដូចខាងក្រោម ៖

(ក) ប្រព័ន្ធបច្ចុប្បន្ន មិនមានទំនោរចាត់ទុកនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រជាផ្នែកមួយនៃមនុស្សជាតិ និងជាមូលដ្ឋានគ្រឹះដែលនាំឱ្យកើតអំពើហិង្សា និងការរើសអើង។ ដូច្នេះ មន្ត្រីរដ្ឋាភិបាល ពុំបានត្រៀមលក្ខណៈឱ្យបានល្អ ដើម្បីដោះស្រាយតម្រូវការជាក់លាក់ជូនក្រុមប្រជាជនទាំងនេះនោះទេ។

(ខ) ករណីនេះ នាំឱ្យមានការព្រួយបារម្ភធំមួយទៀត ៖ កង្វះស្ថិតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងគ្រប់វិស័យ ដែលបណ្តាលពីអវត្តមាននៃវិធីសាស្ត្រដែលសមស្របមួយស្តីពីការកំណត់អត្តសញ្ញាណសាមីខ្លួន ក៏ដូចជា ការប្រមូល និងវិភាគទិន្នន័យ។ ដូច្នេះ ស្ថិតិផ្លូវការអាចនឹងរាយការណ៍ចំនួនឧបទ្ទវហេតុតិចជាងចំនួនជាក់ស្តែង រួមជាមួយការកំណត់ប្រភេទឧបទ្ទវហេតុដោយលម្អៀង និងមិនច្បាស់លាស់ ជាលទ្ធផលនាំឱ្យមានការកំណត់មិនត្រឹមត្រូវ ការលាក់បាំង និងការរាយការណ៍តិចជាងចំនួនជាក់ស្តែង។ ការខកខានជាប្រព័ន្ធក្នុងការប្រមូលទិន្នន័យ ជារឿយៗបណ្តាលឱ្យមើលមិនឃើញកង្វល់ និងបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា។

(គ) ជាលទ្ធផល កង្វះទិន្នន័យធ្វើឱ្យពុំមានគោលនយោបាយសាធារណៈសមស្របដើម្បីឆ្លើយតបនឹងកង្វល់ និងបញ្ហាប្រឈមជាក់លាក់ ដែលសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះ។

២៩. តំណាងរាជរដ្ឋាភិបាលទាំងអស់ ដែលអ្នកជំនាញឯករាជ្យបានជួបពិភាក្សាក្នុងដំណើរទស្សនកិច្ច ទទួលស្គាល់ថាខ្លួនកំពុងប្រឈមនឹងការលំបាកផ្នែកវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ជាពិសេស ការគោរពឯកជនភាពរបស់អ្នកស្រឡាញ់ភេទដូចគ្នា។ ទោះយ៉ាងណាក៏ដោយ អ្នកជំនាញឯករាជ្យទទូចថាបញ្ហាប្រឈមទាំងនោះ មិនមែនជាបញ្ហាដែលពិបាកហួសហេតុពេកនោះទេ ហើយការប្រមូល និងគ្រប់គ្រងទិន្នន័យ គឺជាសមាសធាតុសំខាន់មួយនៃកាតព្វកិច្ចរបស់រដ្ឋក្នុងការទប់ស្កាត់ កាត់ទោស និងផ្តន្ទាទោសចំពោះការរំលោភសិទ្ធិមនុស្ស[24]។

៣០. អ្នកជំនាញឯករាជ្យលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាល ទទួលស្គាល់តួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការប្រមូល និងគ្រប់គ្រងទិន្នន័យទាក់ទងនឹងអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ហើយដូច្នេះ អាចផ្តល់មូលដ្ឋានភស្តុតាងដែលអាចប្រើសម្រាប់បង្កើតគោលនយោបាយសាធារណៈ[25]។

## IV. អំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ

៣១. តំណាងរដ្ឋាភិបាលមួយចំនួន ដែលបានជួបពិភាក្សាជាមួយអ្នកជំនាញឯករាជ្យបានលើក

[24] A/HRC/41/45 កថាខណ្ឌ ៧០។

[25] ដូចខាងលើ កថាខណ្ឌ ៧៧ និង ៨២។

ឡើងថាមិនមានការរើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នានោះទេ។ ដោយសារពុំមានការសិក្សា ឬទិន្នន័យស្ថិតិផ្លូវការ ព័ត៌មានស្ដីពីអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនៅរាយប៉ាយ និងមិនពេញលេញ។

៣២. ទោះជាយ៉ាងនេះក្ដី អ្នកជំនាញឯករាជ្យជឿថាមានភស្តុតាងគ្រប់គ្រាន់បង្ហាញយ៉ាងមុតមាំថា អ្នកស្រឡាញ់ភេទដូចគ្នាប្រឈមអំពើហិង្សា និងការរើសអើងនៅតាមលំនៅដ្ឋាន សាលារៀន កន្លែងធ្វើការ ពេលទទួលសេវាថែទាំសុខភាព និងក្នុងកន្លែងឃុំឃាំង។ អ្នកជំនាញឯករាជ្យបានកំណត់កត្តាកើតឡើងជាប្រព័ន្ធ ដែលបដិសេធសិទ្ធិរស់នៅដោយសេរី និងស្មើភាពរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ ចំណុចសំខាន់គួរកត់សម្គាល់ផងដែរនោះគឺ ការរើសអើងអាចកើតឡើងដោយសារសកម្មភាព ឬអសកម្មភាព ហើយក៏អាចកើតឡើងពីការប្រព្រឹត្តរបស់បុគ្គលឯកជនផងដែរ។

## ក. អំពើហិង្សា និងការបដិសេធក្នុងចំណោមក្រុមគ្រួសារ

៣៣. ទោះបីអ្នកជំនាញឯករាជ្យបានទទួលអំណះអំណាងតិចតួច ស្ដីពីអំពើហិង្សាជាប្រព័ន្ធ ដែលប្រព្រឹត្តដោយរដ្ឋក៏ដោយ របាយការណ៍អំពីករណីទាំងនេះពិតជាមាន ហើយមិនគួរមើលរំលងឡើយ។ ឧទាហរណ៍ ក្នុងឆ្នាំ២០២០ នៅក្នុងលិខិតឆ្លើយឆ្លងរួមគ្នា របស់អ្នកកាន់អាណត្តិជាច្រើននាក់ ផ្ញើជូនរាជរដ្ឋាភិបាលកម្ពុជា បង្ហាញអំពីការព្រួយបារម្ភទាក់ទងនឹងការចោទប្រកាន់អំពីការចាប់ខ្លួន និងឃុំខ្លួនតាមអំពើចិត្តលើស្ត្រីប្តូរយេនឌ័រ ដែលរកស៊ីផ្លូវភេទក្នុងវីដេអូឯកជនដែលបានផ្សព្វផ្សាយលើបណ្ដាញសង្គម ដោយមិនបានសុំការយល់ព្រមពីស្ត្រីនោះ[26]។ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ច អ្នកជំនាញឯករាជ្យ បានទទួលរបាយការណ៍ពីករណីនៃអំពើហិង្សារបស់នគរបាលលើស្ត្រីប្តូរយេនឌ័រ ជាពិសេសអ្នករកស៊ីផ្លូវភេទ[27]។ ការសិក្សាមួយក្នុង ឆ្នាំ២០១៦ បង្ហាញថា អ្នកប្តូរយេនឌ័រពីបុរសទៅជាស្ត្រីចំនួន ៣៨,៧% ដែលត្រូវបានស្ទង់មតិ ត្រូវបាននគរបាលចាប់ខ្លួន យ៉ាងហោចណាស់ម្តង ក្នុងនោះគេជឿថាស្ត្រីចំនួន៩១,៦៧% ត្រូវបានចាប់ខ្លួនដោយសារតែអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ហើយ ៣៣,៥៨% រាយការណ៍ថាពួកគេរងការចោទប្រកាន់មិនត្រឹមត្រូវ ថាបានប្រព្រឹត្តបទល្មើស[28]។ ការស្ទង់មតិក៏បង្ហាញពី ការបៀតបៀន ការសម្លុត និងការរំលោភបំពាន ក្នុងកម្រិតខ្ពស់ ពីសំណាក់កងកម្លាំងនគរបាល។ ឧបទ្ទវហេតុបែបនេះ គឺសំខាន់ណាស់ដែលត្រូវរាយការណ៍ឱ្យត្រឹមត្រូវ ដើម្បីឱ្យជនរងគ្រោះមានសិទ្ធិទទួលបានយុត្តិធម៌ និងនាំជនល្មើសមកទទួលខុសត្រូវ។

៣៤. សង្គមគ្រួសារ ជាកន្លែងចម្បងដែលពោរពេញដោយការរើសអើង និងអំពើហិង្សាផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនៅកម្ពុជា។ ដោយសារតែ តម្លៃគ្រួសារមានសារសំខាន់ ការដែលឪពុកម្តាយមិនអាចទទួលយក ពេលកូនៗបង្ហាញអំពីនិន្នាការភេទខុសប្រពៃណី ឬអត្តសញ្ញាណប្តូរយេនឌ័ររបស់ពួកគេ អាចនឹងពិបាកទទួលយក ហើយក្នុងករណីខ្លះ អាចធ្វើ

[26] សូមមើលលិខិតឆ្លើយឆ្លងលេខ KHM 2/2020 សូមមើលគេហទំព័រ https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?gId=25225, និងលិខិតឆ្លើយតប, សូមមើលគេហទំព័រ https://spcommreports.ohchr.org/TMResultsBase/DownLoadFile?gId=35452។

[27] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងស្ថាប័នផ្សេងទៀត របាយការណ៍រួមដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស កថាខណ្ឌ ៣១។

[28] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា “ការរើសអើងចំពោះអ្នកប្តូរយេនឌ័រពីបុរសទៅជាស្ត្រីនៅតាមទីប្រជុំជនកម្ពុជា” ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ ១៨-២០ សូមមើលគេហទំព័រ https://cchrcambodia.org/en/publications/general-reports/115.

ឱ្យចំណងគ្រួសារបែកបាក់ទៀតផង។ ការខកចិត្តរបស់ឪពុកម្តាយអ្នកស្រឡាញ់ភេទដូចគ្នា ទំនងដោយសារតែភ័យខ្លាចថាកូនរបស់ពួកគេ មិនមានជីវិតរស់នៅដោយរីករាយ ក៏ដូចជា ភ័យខ្លាចចំពោះការនិយាយខ្សឹបខ្សៀវពីគ្រួសាររបស់ពួកគេ។ អ្នកជំនាញឯករាជ្យបានស្តាប់ការរៀបរាប់របស់កូនៗជាអ្នកស្រឡាញ់ភេទដូចគ្នា ដែលត្រូវបានគ្រួសារគំរាមកំហែង ថានឹងមិនទទួលស្គាល់ បណ្តេញចេញពីផ្ទះ ឬបញ្ឈប់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ធ្វើឱ្យពួកគេមិនអាចបន្តការសិក្សា និងប្រឈមភាពក្រីក្រ។

៣៥. បុគ្គលមាននិន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះយ៉ាងច្រើនលើសលប់រាយការណ៍ថា ប្រតិកម្មដំបូងពីឪពុកម្តាយរបស់ពួកគេគឺការព្យាយាម "កែប្រែ" ពួកគេ ឧទាហរណ៍ ដោយបំបែកពួកគេចេញពីដៃគូ បញ្ជូនពួកគេទៅឆ្ងាយ ឬបង្ខំពួកគេឱ្យធ្វើកិច្ចការផ្ទះដែលមើលឃើញថាសមនឹងភេទពីកំណើត។ ការសិក្សាបង្ហាញថា គ្រួសារច្រើនជាង ៣/៤ នៅកម្ពុជាព្យាយាមបង្ខំកូនៗដែលជាអ្នកស្រឡាញ់ភេទដូចគ្នាឱ្យ "ប្តូរ" និន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ រួមទាំងតាមរយៈការរៀបចំអាពាហ៍ពិពាហ៍ ឬបំបែកកូនពីដៃគូភេទដូចគ្នា។ លើសពីនេះ ឪពុកម្តាយស្ទើរតែពាក់កណ្តាលបដិសេធមិនទទួលស្គាល់កូនរបស់ខ្លួន ប្រសិនបើពួកគេមិនផ្លាស់ប្តូរនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ[29]។ របាយការណ៍បង្ហាញថា ឪពុកម្តាយ បាននាំកូនដែលជាអ្នកស្រឡាញ់ភេទដូចគ្នាទៅរកគ្រូបុរាណដើម្បី "ព្យាបាល" ហើយ "ការព្យាបាល" ទាំងនោះ ពេលខ្លះ មានទាំងការដាក់ទណ្ឌកម្មលើរាងកាយ[30]។

៣៦. អ្នកជំនាញឯករាជ្យបញ្ជាក់ជាថ្មីថា ការអនុវត្តការកែប្រែចិត្តបែបបង្ខំ មានចរិតលក្ខណៈជាការរើសអើង បន្ថោកតម្លៃ អមនុស្សធម៌ និងឃោរឃៅ ហើយអាចនឹងត្រូវបានចាត់ទុកថាជាការធ្វើទារុណកម្ម ដែលបង្កឱ្យមានការប៉ះទង្គិចផ្លូវចិត្ត និងរាងកាយយ៉ាងធ្ងន់ធ្ងរ។ ការអនុវត្តបែបនេះអាចពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋ ដូចមានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ បើទោះបីជាត្រូវបានប្រព្រឹត្តដោយតួអង្គឯកជនក៏ដោយ[31]។

៣៧. ការរើសអើង និងអំពើហិង្សាក៏អាចកើតចេញពីសមាជិកគ្រួសារផ្សេងទៀតដែរ ដូចជាបងប្អូនបង្កើត ជីដូនជីតា មីង ឬពូ។ អ្នកជំនាញឯករាជ្យបានទទួលរបាយការណ៍ពីការយាយីក្នុងរង្វង់គ្រួសារដោយបុរេនិច្ឆ័យ និងការមាក់ងាយ ដូចជា ការសន្មតជាមុនថាអ្នកមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះ ជាមនុស្សឈឺ ងាយប្រព្រឹត្តអំពើលួចឆក់ និងមិនអាចជឿទុកចិត្តបាន។

៣៨. ការសិក្សាស្តីពីអំពើហិង្សាក្នុងគ្រួសារ ឆ្នាំ២០១៩ បានបង្ហាញថា ៨១% នៃស្ត្រីស្រឡាញ់ភេទដូចគ្នា ស្ត្រីស្រឡាញ់ភេទទាំងពីរ និងបុរសប្តូរយេនឌ័រអាយុក្រោម ៣៥ឆ្នាំ ប្រឈមអំពើហិង្សាផ្លូវចិត្តក្នុងគ្រួសារ ហើយចំនួន ១០% រងអំពើហិង្សាផ្លូវភេទ ជាទូទៅ ក្នុងជីវិតអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយចំនួន ៣៥% ធ្លាប់គិត ឬប៉ុនប៉ងធ្វើអត្តឃាត ក្នុងអំឡុងពេលណាមួយនៃជីវិតពួកគេ ដោយសារតែគ្រួសារបដិសេធមិនទទួលស្គាល់និន្នាការភេទ ឬ

[29] Taylor Nelson Sofres កម្ពុជា និងសហគមន៍ឥន្ទធនូកម្ពុជា *ទស្សនៈយល់ឃើញ ឥរិយាបទ និងអាកប្បកិរិយាចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា* (ឆ្នាំ២០១៥)។

[30] A/HRC/44/53 កថាខណ្ឌ ៤៨។

[31] ដូចខាងលើ កថាខណ្ឌ ៨៣-៨៦។

អត្តសញ្ញាណ និងការបង្ហាញយេនឌ័ររបស់ពួកគេ[32]។

៣៩. តំណាងរាជរដ្ឋាភិបាលទាំងអស់ ដែលអ្នកជំនាញឯករាជ្យបានជួបពិភាក្សាក្នុងដំណើរទស្សនកិច្ច បានដឹងអំពីបញ្ហានេះ និងបានលើកឡើងអំពីសារសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងអំពីភាពចម្រុះនៃភេទ និងយេនឌ័រក្នុងគ្រួសារ ដែលជាជំហានចាំបាច់ដំបូង សំដៅលុបបំបាត់អំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាបានផ្តល់អនុសាសន៍គួរតែមានការយកចិត្តទុកដាក់ជាពិសេស ដើម្បីដោះស្រាយអំពើហិង្សាលើអ្នកស្រឡាញ់ភេទដូចគ្នា និងអន្តរភេទ ដើម្បីបង្ហាញកិច្ចខិតខំប្រឹងប្រែងមួយផ្នែករបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រ[33]។

## ខ. ការអប់រំ

៤០. ការស្ទង់មតិក្នុងចំណោមយុវជនស្រឡាញ់ភេទដូចគ្នាឆ្នាំ ២០១៥ បង្ហាញថា ស្ទើរតែ ៦៣% នៃអ្នកឆ្លើយសំណួរ ធ្លាប់បានគេសម្លុតគំរាម និងចំអក ពេលពួកគេរៀននៅសាលា ហើយ ៩៤% យល់ថាការសម្លុតគំរាម និងចំអកនេះ អាចដោយសារនិន្នាការភេទ ឬអត្តសញ្ញាណ និងការបង្ហាញយេនឌ័ររបស់ពួកគេ មួយផ្នែក ឬដោយសារចំណុចនេះទាំងស្រុងតែម្តង[34]។ ទិន្នន័យដែលប្រមូលបានបង្ហាញភស្តុតាងថា ការសម្លុតគំរាម និងចំអកដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ គឺកើតមានច្រើននៅតាមសាលារៀនកម្ពុជាតាមរយៈពាក្យសម្តី ការមិនរាប់រក ការបៀតបៀនលើរូបរាងកាយ និងការបំពាន និងការយាយីផ្លូវភេទ ដែលបានរាយការណ៍ដោយមនុស្សចំនួន ដល់ទៅ ១/៣ នៃអ្នកចូលរួមក្នុងការស្ទង់មតិសរុប[35]។

៤១. ការសម្លុតគំរាម និងចំអកអាច ធ្វើឡើងដោយមិត្តភក្តិ ឬគ្រូបង្រៀន ហើយក៏ពាក់ព័ន្ធនឹងការកំណត់ក្រឹត្យក្រមយេនឌ័រតឹងរ៉ឹងក្នុងវិធាន និងបទបញ្ញាសាលារៀនដែរ។ វិន័យស្លៀកពាក់តាមសាលារៀន បង្កបញ្ហាដល់សិស្សដែលបង្ហាញយេនឌ័រតាមរយៈការស្លៀកពាក់ និងអាចមើលឃើញថាមិនត្រឹមត្រូវតាមវិន័យ ជាពិសេស ការកាត់សក់ និងឯកសណ្ឋាន។

៤២. ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជាក់ថា ថ្មីៗនេះ ក្រសួងបានចេញគោលការណ៍ណែនាំដល់សាលារៀន ឱ្យប្រើវិធីសាស្រ្តបត់បែនទាក់ទងនឹងការស្លៀកពាក់ ហើយសិស្សគ្រប់ភេទទាំងអស់ មានសេរីភាពទុកសក់វែង ឬខ្លីបាន។ ប៉ុន្តែ ភស្តុតាងដែលបានទទួល នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តបាត់ដំបង បង្ហាញថាសាលារៀននានាមិនទាន់បានអនុវត្តតាមគោលការណ៍ណែនាំទាំងនេះ បានស៊ីសង្វាក់គ្នានៅឡើយទេ។ ករណីនេះអាចជាឧបសគ្គដ៏ធ្ងន់ធ្ងរមួយ ៖ យុវជន អាយុ ១៩ឆ្នាំ ដែលមានយេនឌ័រចម្រុះបានពន្យល់ថា គេសម្រេចចិត្តឈប់រៀនត្រឹមថ្នាក់ទី១២ មុនពេលទទួលសញ្ញាបត្រទុតិយភូមិ ដោយសារតែគេមិនអាចបង្ហាញអត្តសញ្ញាណយេនឌ័ររបស់ខ្លួនបាន។ អ្នកជំនាញឯករាជ្យ ក៏បានឮពីករណី

---

[32] សហគមន៍ឥន្ទធនូកម្ពុជា "អំពើហិង្សាក្នុងគ្រួសារមកលើស្រ្តីស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរយេនឌ័រ (LBT) នៅកម្ពុជា" ខែមិថុនា ឆ្នាំ២០១៩។

[33] A/HRC/36/61 កថាខណ្ឌ ៣៨។

[34] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសកម្ពុជា" ខែធ្នូ ឆ្នាំ២០១៥ ទំព័រ ១៦។

[35] ដូចខាងលើ។

ដែលសិស្សត្រូវបានបង្ខំឱ្យចេញពីសាលា ដោយសារការមិនគោរពវិន័យស្លៀកពាក់ ឬដោយសារពួកគេខ្លាចគ្រូៗដែលគំរាមកាត់សក់ពួកគេ។ អ្នកប្តូរយេនឌ័រ និងអ្នកមានយេនឌ័រចម្រុះជាច្រើននាក់បានរៀបរាប់ថា គេចាំរហូតដល់បញ្ចប់ការសិក្សាទើបហ៊ានបង្ហាញអត្តសញ្ញាណយេនឌ័រ ដោយសារខ្លាចមានផលប៉ះពាល់អវិជ្ជមានដល់ការរៀនសូត្រ។ ទោះជាយ៉ាងនេះក្តី ករណីមួយចំនួន ការសម្រេចចិត្តបែបនេះអាចបង្កជាបញ្ហាថ្មីនាពេលអនាគត។ ជាការពិតណាស់ ភាពមិនស៊ីសង្វាក់គ្នារវាងរូបថតលើវិញ្ញាបនបត្របញ្ជាក់ការសិក្សា និងរូបរាងខាងក្រៅ ខណៈដែលពួកគេកំពុងស្វែងរកការងារ ជាឧបសគ្គមួយក្នុងជីវិតការងារ។

៤៣. ចំណុចចុងក្រោយ អ្នកជំនាញឯករាជ្យមានការព្រួយបារម្ភចំពោះចន្លោះប្រហោងក្នុងបទប្បញ្ញត្តិស្តីពីការផ្តល់ការអប់រំគ្រប់ជ្រុងជ្រោយអំពីបញ្ហាផ្លូវភេទ និងយេនឌ័រ រួមទាំងគោលគំនិតនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ លោកស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយនឹងក្រសួងសុខាភិបាល ក្នុងការអនុវត្តកម្មវិធីសិក្សាអប់រំសុខភាពថ្មីមួយ ដែលផ្នែកមួយនៃការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ រួមបញ្ចូលនូវគោលគំនិតនៃនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងសុខភាពផ្លូវភេទ និងបន្តពូជ។ អ្នកជំនាញឯករាជ្យលើកទឹកចិត្តឱ្យរដ្ឋាភិបាលបន្តអនុវត្តកម្មវិធីសិក្សានេះ និងធានារួមបញ្ចូលនូវនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងសម្ភារៈបណ្តុះបណ្តាលពាក់ព័ន្ធទាំងអស់ រួមទាំងការបណ្តុះបណ្តាលគ្រូបង្រៀន និងក្នុងសៀវភៅសិក្សាគោលរបស់សិស្ស។

៤៤. សង្គមស៊ីវិលកម្ពុជាបានគូសបញ្ជាក់ថា ការបង្កើនការយល់ដឹងតាមរយៈសិក្ខាសាលាសិទ្ធិមនុស្សស្តីពីនិន្នាការភេទ ឬ អត្តសញ្ញាណ និងការបង្ហាញយេនឌ័រ ឬលក្ខណៈភេទ និងតាមរយៈការបណ្តុះបណ្តាល ឧបករណ៍ សម្ភារៈ និងការបញ្ចូលក្នុងកម្មវិធីសិក្សាអប់រំអំពីបញ្ហាទាក់ទងនឹងនិន្នាការភេទ ឬ អត្តសញ្ញាណ និងការបង្ហាញយេនឌ័រ ឬបុគ្គលិកលក្ខណៈភេទ នឹងជួយយ៉ាងធំធេងក្នុងការជំរុញការទទួលយកអ្នកស្រឡាញ់ភេទដូចគ្នា។

## គ. វិស័យការងារ និងកិច្ចគាំពារសង្គម

៤៥. ទោះបីជានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រមិនត្រូវបានគេទទួលស្គាល់ជាក់លាក់ថាជាមូលដ្ឋានហាមប្រាមកុំឱ្យមានការរើសអើងក៏ដោយ មាត្រា ១២ នៃច្បាប់ការងារមានបទប្បញ្ញត្តិចែងពីការមិនរើសអើងក្នុងវិស័យការងារ រាប់បញ្ចូលទាំងដោយមូលដ្ឋានភេទទៀតផង។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់យ៉ាងច្បាស់ថា ក្រសួងពុំដែលទទួលបានការរាយការណ៍ពីករណីរើសអើងផ្អែកលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ នោះទេ ប៉ុន្តែការរើសអើងបែបនេះក៏ចាត់ទុកក្នុងមូលដ្ឋាននៃភេទ ដូច្នេះ នឹងអាចត្រូវបានចាត់ទុកថាជាទម្រង់នៃការរើសអើងធ្ងន់ធ្ងរ។ ទោះជាយ៉ាងនេះក្តី ការដែលក្រសួងពុំធ្លាប់ទទួលបានពាក្យបណ្តឹងពីការរើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ពុំស៊ីសង្វាក់នឹងរឿងរ៉ាវជាច្រើនដែលអ្នកជំនាញឯករាជ្យទទួលបាន ឬអាចដោយសារតែបញ្ហាកង្វះទិន្នន័យ។

៤៦. ឧទាហរណ៍ ក្នុងការស្ទង់មតិ ឆ្នាំ២០១៦ ជាមួយអ្នកប្តូរយេនឌ័រពីបុរសទៅជាស្ត្រី មានអ្នកផ្តល់ចម្លើយឆ្លើយជាង១/៣ រាយការណ៍ថា ពួកគេត្រូវបានបដិសេធមិនឱ្យការងារធ្វើដោយសារតែពួកគេជាអ្នកប្តូរយេនឌ័រ ហើយ ២៧% បានលើកឡើងថា ពួកគេត្រូវបានបណ្តេញ

ចេញពីការងារដោយសារតែអត្តសញ្ញាណយេនឌ័រ[36]។ ដោយសារកង្វះការទទួលស្គាល់តាមផ្លូវច្បាប់នៃអត្តសញ្ញាណយេនឌ័រ អ្នកប្តូរយេនឌ័រ និងអ្នកមានភេទចម្រុះ ប្រឈមឧបសគ្គខ្លាំងក្នុងការទទួលបានការងារ ដោយសារភាពមិនស៊ីសង្វាក់គ្នារវាងការសម្គាល់យេនឌ័រលើអត្តសញ្ញាណប័ណ្ណ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ (ក៏ដូចជាការបង្ហាញយេនឌ័រ រួមទាំងម៉ូតសក់ដែរ)។

៤៧. អ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងប្រទេសបានប្រាប់អ្នកជំនាញឯករាជ្យថា ជារឿយៗពួកគេត្រូវបានអញ្ជើញឱ្យទៅសម្ភាសការងារ សម្រាប់មុខតំណែងដែលត្រូវនឹងគុណវុឌ្ឍិរបស់ពួកគេ ប៉ុន្តែពួកគេមិនត្រូវបានជ្រើសរើសឱ្យចូលធ្វើការងារបន្ទាប់ពីសម្ភាសហើយ ដោយសារតែនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ។ ពួកគេភាគច្រើនពុំបានបង្ហាញអត្តសញ្ញាណដល់និយោជក ដោយសារខ្លាចមានការបណ្តេញចេញ ឬមិនឱ្យធ្វើការ។ បុគ្គលមួយចំនួនពន្យល់ថា មុខតំណែងទាក់ទងនឹងវិស័យបដិសណ្ឋារកិច្ច និងសេវាកម្ម នឹងផ្តល់ទៅអ្នកស្រឡាញ់ភេទដូចគ្នានោះទេ ដោយសារមានការសង្ស័យថា ពួកគេជាចោរ អ្នករកស៊ីផ្លូវភេទ ឬខ្លះទៀតថាជាមនុស្សអសីលធម៌។ ភាគច្រើន ការងាររោងចក្រ របររកស៊ីផ្លូវភេទ និងការងារក្នុងវិស័យកែសម្ផស្ស ជាជម្រើសការងារតែមួយសម្រាប់ពួកគេ[37]។ អ្នកជំនាញឯករាជ្យកត់សម្គាល់ឃើញថា ដោយសារអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកមានយេនឌ័រចម្រុះផ្សេងទៀតនៅកម្ពុជា បោះបង់ចោលការសិក្សាលឿនជាងក្រុមប្រជាជនដទៃ ពួកគេភាគច្រើនធ្វើតែការងារដែលពុំសូវត្រូវការជំនាញ។

៤៨. នៅកន្លែងធ្វើការ អ្នកមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះ តែងតែទទួលរងនូវការចំអក និងបៀតបៀនពីមិត្តរួមការងារ។ គ្រូបង្រៀនជាច្រើន ធ្វើការនៅសាលារៀនឯកជនតាមបណ្តាខេត្ត ដែលបង្ហាញជាចំហថាជាបុរសស្រឡាញ់បុរស ឬត្រូវបានមិត្តរួមការងារសន្មតថាជាបុរសស្រឡាញ់បុរស បានរាយការណ៍ថា មិត្តរួមការងាររបស់ពួកគេបានចាត់ទុកថាការស្នាបអង្អែល និងទះគូថពួកគេលេងជារឿងដែលអាចទទួលយកបាន ដោយសារតែនិន្នាការភេទរបស់ពួកគេ។ និទណ្ឌភាពចំពោះអាកប្បកិរិយាបុគ្គលបែបនេះរួមចំណែកដល់ការបង្កើតបរិយាកាសអសុវត្ថិភាព សម្រាប់បុគ្គលិកដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ហើយដែលធ្វើឱ្យពួកគេពិបាកនឹងរីកចម្រើនក្នុងវិស័យការងារ។

៤៩. ការរើសអើងក្នុងវិស័យការងារ នឹងធ្វើឱ្យអ្នកស្រឡាញ់ភេទដូចគ្នាទទួលបានឱកាសការងារកាន់តែតិចជាងមុន ដោយជៀសមិនរួច ដែលនេះរួមចំណែកដល់អត្រានៃភាពក្រីក្រកាន់តែខ្ពស់ ក្នុងចំណោមអ្នកស្រឡាញ់ភេទដូចគ្នា។ ជាញឹកញាប់ ពួកគេច្រើនតែធ្វើការងារក្នុងវិស័យក្រៅប្រព័ន្ធ ធ្វើឱ្យពួកគេមិនអាចជៀសផុតពីភាពក្រីក្រ។ ករណីនេះកាន់តែធ្ងន់ធ្ងរឡើង ដោយសារតែការបដិសេធរបស់គ្រួសារ និងការមិនរាប់រកនៅសាលារៀន និងសហគមន៍ទាំងមូល[38]។ អ្នកស្រឡាញ់ភេទដូចគ្នាទទួលរងផលប៉ះពាល់ជាពិសេស ដោយសារវិបត្តិនៃជំងឺកូវីដ-១៩។ អ្នកខ្លះពឹងលើជំនួយស្បៀងអាហារសង្គ្រោះបន្ទាន់ ដែលផ្តល់ដោយអង្គការសង្គម

[36] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា “ការរើសអើងប្រឆាំងស្ត្រីប្តូរយេនឌ័រតាមទីប្រជុំជននៅកម្ពុជា” ទំព័រ ១៦ និងទំព័រ ១៧។

[37] សូមមើលផងដែរ A/HRC/42/60/Add.1 កថាខណ្ឌ ៦០។

[38] ដូចខាងលើ។

ស៊ីវិល[39]។ របាយការណ៍បង្ហាញថា អ្នកប្តូរយេនឌ័រពីបុរសទៅជាស្ត្រី ប្រឈមខ្លាំងនឹងអសន្តិសុខស្បៀង ហើយភាគច្រើនធ្វើចំណាកស្រុក ទៅកាន់ប្រទេសជិតខាងដើម្បីស្វែងរកឱកាសការងារ[40]។

៥០. លទ្ធភាពទទួលបានសេវាសាធារណៈ និងពីស្ថាប័ន ក្នុងករណីខ្លះ នៅតែជាបញ្ហា ពីព្រោះអ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននាក់ផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅញឹកញាប់ និងធ្វើការក្នុងវិស័យការងារក្រៅប្រព័ន្ធ ដូច្នេះពួកគេមិនមានឯកសារផ្លូវច្បាប់គ្រប់គ្រាន់ក្នុងការទទួលបានអត្តសញ្ញាណប័ណ្ណ និងដើម្បីអាចមានសិទ្ធិទទួលបានអត្ថប្រយោជន៍ពីបេឡាជាតិសន្តិសុខសង្គម។ ករណីនេះធ្វើឱ្យសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ទទួលបានកិច្ចការពារសង្គមដែលពុំសូវមានប្រសិទ្ធភាព ដោយសារតែការទទួលបានសេវាសាធារណៈ និងពីស្ថាប័នមានភាពស្មុគស្មាញសម្រាប់ពួកគេជាងក្រុមប្រជាជនដទៃទៀត។ ស្ថានភាពនេះកាន់តែពិបាក ជាពិសេស សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាដែលមានវ័យចំណាស់ ដែលជារឿយៗត្រូវបានគេផាត់ចោល ប្រឈមអសន្តិសុខលំនៅដ្ឋាន និងមិនអាចទទួលបានសេវាកម្ម និងអត្ថប្រយោជន៍នានា ដែលគូស្វាមីភរិយាស្របច្បាប់ទទួលបាន។

៥១. បុគ្គលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះ ជាផ្នែកមួយនៃសង្គមកម្ពុជា ហើយទេពកោសល្យ និងសមត្ថភាពរបស់ពួកគេអាចដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិ។ ដើម្បីសម្រេចបាននូវសក្តានុពលនេះ ចាំបាច់ត្រូវកំណត់លក្ខខណ្ឌធានាថាអ្នកស្រឡាញ់ភេទដូចគ្នាអាចធ្វើអ្វីបានពេញលេញដោយខ្លួនឯង និងអាចទទួលបានមុខតំណែងនៅក្នុងគ្រប់វិស័យសេដ្ឋកិច្ចក្នុងសង្គមកម្ពុជា។

៥២. ក្នុងបរិបទនេះ អ្នកជំនាញឯករាជ្យលើកទឹកចិត្តកម្ពុជា ចំពោះគោលបំណងអនុម័តច្បាប់ប្រឆាំងការរើសអើងក្នុងក្របខណ្ឌទូលំទូលាយមួយ។ លោកបានផ្តល់អនុសាសន៍បន្ថែមលើការរៀបចំការស្ទង់មតិ និងសិក្សាអំពីស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នានៅតាមកន្លែងធ្វើការ និងយុទ្ធនាការផ្សព្វផ្សាយគោលនយោបាយរបស់រដ្ឋាភិបាល ដែលនឹងមិនអត់ឱនចំពោះការរើសអើងដោយសារនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ លើសពីនេះ ជនរងគ្រោះត្រូវមានសិទ្ធិទទួលបានយុត្តិធម៌ និងមានយន្តការរាយការណ៍ និងស្វែងរកសំណង។

## ឃ. វិស័យសុខាភិបាល

៥៣. យោងតាមព័ត៌មានផ្តល់ដោយ កម្មវិធីរួមរបស់អង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍ អត្រាប្រេវ៉ាឡង់ផ្ទុកមេរោគអេដស៍មានអត្រាខ្ពស់ ក្នុងចំណោមអ្នកប្តូរយេនឌ័រពីបុរសទៅជាស្ត្រី (៩,៦%) និងបុរសរួមភេទជាមួយបុរស (៤%) បើប្រៀបធៀបជាមួយប្រជាជនទូទៅ (០,៦%)។ អ្នកជំនាញឯករាជ្យកត់សម្គាល់ថា បណ្តាញតួអង្គរដ្ឋាភិបាល និងតួអង្គមិនមែនរដ្ឋាភិបាលក្នុងប្រទេស បានអនុវត្តកម្មវិធីទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍ បានយ៉ាងល្អ

[39] Sayoni, *Making the Invisible Visible in Southeast Asia: How COVID-19 Escalates Violence and Discrimination against LBQ Communities* (2020), ទំព័រ ៣៦ សូមមើលគេហទំព័រ https://drive.google.com/file/d/1F0PDd1J7btrILgg3EscTalIFMFBPKy9X/view?fbclid=IwAR3stWs9r kppRYzIW0spsuK3LyV-eKYa9dQro4b4TTCb234DgvSsJ95DP70.

[40] ILGA Asia, "ឥន្ទធនូនៅពេលភ្លៀងធ្លាក់៖ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាស្វែងរកសេរីភាព និងសមភាព" (ឆ្នាំ២០២១) ទំព័រ ១១ សូមមើលគេហទំព័រ https://static1.squarespace.com/static/5a84777f64b05fa9644483fe/t/613197e0eeba791169f29af7/1630640195116/ILGA+ASIA+Country+Report_CAMBODIA.pdf.

ប្រសើរ និងធ្វើឱ្យរដ្ឋាភិបាលកំណត់គោលដៅលុបបំបាត់ជំងឺអេដស៍ត្រឹមឆ្នាំ២០២៥។ លោកស្វាគមន៍ចំពោះការណែនាំនូវវិធានការណ៍បង្ការថ្មីៗ (ឱសថបង្ការការឆ្លងមេរោគអេដស៍មុនពេលប្រព្រឹត្តប្រឈម ឬ ហៅថា ប្រិព) សម្រាប់ក្រុមប្រជាជនចម្បងៗ រួមទាំងបុរសរួមភេទជាមួយបុរស អ្នកប្តូរយេនឌ័រពីបុរសទៅជាស្ត្រី និងអ្នករកស៊ីផ្លូវភេទ។ ការគោរពរបស់រដ្ឋាភិបាលចំពោះ ភាពជាដៃគូសាកលសម្រាប់សកម្មភាព លុបបំបាត់រាល់ទម្រង់នៃការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍ នៅខែធ្នូ ឆ្នាំ២០២២ គឺជាជំហានដ៏ល្អមួយ ក៏ប៉ុន្តែ គួរមានផែនការសកម្មភាពបន្ត ដែលបញ្ចូលក្តីកង្វល់ទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

៥៤. ចំណុចនៃការព្រួយបារម្ភមួយគឺថាមានការប្រមូលទិន្នន័យ ឬភស្តុតាងតិចតួចបំផុតទាក់ទងនឹងផលប៉ះពាល់នៃមេរោគអេដស៍/ជំងឺអេដស៍ លើក្រុមដែលមិនស្ថិតក្នុងចំណោមប្រជាជនសំខាន់ៗ ដូចជា ស្ត្រីស្រឡាញ់ស្ត្រី អ្នកប្តូរយេនឌ័រពីស្ត្រីទៅជាបុរស និងអ្នកស្រឡាញ់ភេទទាំងពីរ ក៏ដូចជាការបែងចែកសេវាសុខភាព ដែលឆ្លើយតបនឹងតម្រូវការរបស់អ្នកស្រឡាញ់ភេទដូចគ្នា ជាទូទៅ។

៥៥. បុគ្គលដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះ បានរាយការណ៍ថាមានការរើសអើង និងឧបសគ្គកាន់តែខ្លាំងឡើងក្នុងការទទួលបានសេវាសុខភាព ដោយសារមិនមានបទប្បញ្ញត្តិ និងគោលនយោបាយប្រឆាំងនឹងការរើសអើង ដែលចែងពីការទទួលបានការព្យាបាលដោយស្មើភាពគ្នាក្នុងវិស័យសុខាភិបាល[41]។ អ្នកផ្តល់សេវាសុខភាព ជារឿយៗសួរសំណួរមិនសមរម្យអំពីអត្តសញ្ញាណភេទ និងយេនឌ័រ ហើយក្នុងករណីមួយចំនួន មានការរារាំងការទទួលបានសេវាថែទាំសុខភាពតែម្តង។

៥៦. អ្នកប្តូរយេនឌ័រមួយចំនួន បានបង្ហាញពីភាពលំបាកពេលបង្ហាញអត្តសញ្ញាណប័ណ្ណ ដែលខុសពីអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ឬពេលបំពេញទម្រង់បែបបទនៅតាមមន្ទីរពេទ្យ ដែលមានត្រឹមតែ "ប្រុស" និង "ស្រី" ប៉ុណ្ណោះ។ ពួកគេក៏បានពន្យល់ទៀតថា នៅក្នុងករណីអវត្តមាននៃការបណ្តុះបណ្តាលឯកទេសលើបញ្ហាទាក់ទងនឹងអត្តសញ្ញាណយេនឌ័រ ដល់អ្នកផ្តល់សេវាសុខភាព ពួកគេបានទទួលការព្យាបាលដូចអ្នកជំងឺទៅតាមភេទកំណើតដោយមិនគិតអំពីតម្រូវការជាក់លាក់របស់ពួកគេ។

៥៧. កង្វះព័ត៌មាន និងលទ្ធភាពទទួលបានការថែទាំសុខភាពបញ្ជាក់យេនឌ័រសម្រាប់អ្នកប្តូរយេនឌ័រ និងអ្នកមានភេទចម្រុះ គឺជាបញ្ហាសំខាន់។ ថ្វីត្បិតតែគ្លីនិកឯកជនមួយចំនួនបានផ្តល់ការព្យាបាលដោយអរម៉ូនក៏ដោយ ការព្យាបាលទាំងនោះមានតម្លៃថ្លៃ និងផ្តល់ជូនតែនៅក្នុងខេត្តមួយចំនួនប៉ុណ្ណោះ និងដោយគ្មានការគ្រប់គ្រងត្រឹមត្រូវ។ ដូច្នេះ ការព្យាបាលទាំងនេះមិនអាចជំនួសការព្យាបាល ដែលផ្តល់ដោយសេវាសុខភាពសាធារណៈបាននោះទេ។ នៅពេលមិនអាចរកការព្យាបាលក្នុងប្រទេសបាន អ្នកប្តូរយេនឌ័រ និងអ្នកមានយេនឌ័រចម្រុះងាកទៅរកការអនុវត្តដែលមានគ្រោះថ្នាក់ ដូចជា ការចាក់ស៊ីលីកូន ឬ ការប្រើថ្នាំអរម៉ូនព្យាបាលខ្លួនឯង ដោយពុំមានការពិនិត្យទៀងទាត់ ដោយមិនមានព័ត៌មានពីហានិភ័យ និងផលប៉ះពាល់នៃការព្យាបាលបញ្ជាក់យេនឌ័របែបនេះ។ ពួកគេភាគច្រើនមានអារម្មណ៍ថាត្រូវ

[41] Sayoni, *ធ្វើអ្វីដែលមើលមិនឃើញឱ្យអាចមើលឃើញបាន* ទំព័រ ៣៨។

បង្ខំចិត្តធ្វើដំណើរទៅកាន់ប្រទេសជិតខាង ដើម្បីស្វែងរកការព្យាបាល និងការវះកាត់បញ្ជាក់យេនឌ័រ[42]។ ក្នុងអំឡុងពេលនៃវិបត្តិកូវីដ ១៩ ដំណោះស្រាយបែបនេះថែមទាំងពុំអាចធ្វើបានទៀតផង ដោយសារការបិទច្រកព្រំដែន និងការរឹតត្បិតលើការធ្វើដំណើរ[43]។

៥៨. អ្នកមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះនៅកម្ពុជា ក៏ប្រឈមហានិភ័យនៃបញ្ហាសុខភាពផ្លូវចិត្តច្រើនជាងមុនផងដែរ។ ឧទាហរណ៍ អ្នកស្រឡាញ់ភេទដូចគ្នាមានអត្រាថប់បារម្ភស្រួចស្រាវខ្ពស់ធៀបនឹងប្រជាជនទូទៅ ហើយពួកគេតែងតែមានការលំបាកខាងផ្លូវអារម្មណ៍ខ្លាំង ដែលជាសូចនាករទូទៅនៃការថប់បារម្ភ និងជំងឺបាក់ទឹកចិត្ត ទាក់ទងដោយផ្ទាល់នឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ[44]។ បញ្ហាផ្លូវអារម្មណ៍ និងជំងឺបាក់ទឹកចិត្តកាន់តែមានសភាពធ្ងន់ធ្ងរដោយសារអំពើហិង្សាក្នុងគ្រួសារ[45]។ អ្នកមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះ ត្រូវតែមានលទ្ធភាពទទួលបានការគាំទ្រ និងការព្យាបាលផ្លូវចិត្តជាក់លាក់ទៅតាមតម្រូវការរបស់ពួកគេ និងត្រូវផ្តល់ដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្រដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវ។

៥៩. វិធានការដូចបានជូនជាអនុសាសន៍រួចហើយ ជាពិសេស ច្បាប់ប្រឆាំងការរើសអើង និងវិធានការគោលនយោបាយ ការទទួលស្គាល់អាពាហ៍ពិពាហ៍ភេទដូចគ្នា និងការទទួលស្គាល់អត្តសញ្ញាណយេនឌ័រតាមផ្លូវច្បាប់ អាចមានផលប៉ះពាល់វិជ្ជមានដល់ការទទួលបានសេវាសុខភាពក្នុងកម្រិតខ្ពស់បំផុត។ លើសពីនេះ វិធានការគោលនយោបាយដែលបានដាក់ចេញគួរអនុវត្តអមជាមួយផែនការសកម្មភាពដែលធានាថា និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រត្រូវបានរួមបញ្ចូលក្នុងការប្រមូលទិន្នន័យ ដោយត្រូវមានសូចនាករ និងចំណុចគោលសម្រាប់វាស់វែង អំពីផលវិបាកនៃគោលនយោបាយ ដោយប្រើទិន្នន័យទាំងនោះ ។

## ង. ទីតាំងឃុំឃាំង

៦០. ក្នុងពេលនៃដំណើរទស្សនកិច្ច នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងមហាផ្ទៃបានទទួលស្គាល់យ៉ាងច្បាស់ថា ភាពចម្រុះភេទ និងយេនឌ័រ ក៏មានក្នុងចំណោមអ្នកដែលកំពុងជាប់ពន្ធនាគារដែរ។ អ្នកជំនាញឯករាជ្យបានទទួលព័ត៌មានថា ការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍នៅទីតាំងឃុំឃាំងជាការងារអាទិភាពមួយ អ្នកទោសក៏អាចទទួលសេវាព្យាបាលមេរោគអេដស៍នៅក្នុងពន្ធនាគារបានដែរ។

៦១. ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាព្រួយបារម្ភមួយចំនួនត្រូវបានលើកឡើង ដូចជាវិធានតឹងរ៉ឹងដែលរារាំងស្ត្រីមិនឱ្យកាត់សក់ខ្លី និងបុរសមិនឱ្យទុកសក់វែង ក៏ដូចជាករណីដែលអ្នកប្តូរយេនឌ័រ ត្រូវបានឃុំខ្លួនជាប្រព័ន្ធក្នុងបន្ទប់ឃុំឃាំងតាមភេទពីកំណើត។ ក្នុងលិខិតដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា ក្នុងឆ្នាំ២០២០ អ្នកកាន់អាណត្តិនីតិវិធីពិសេសមួយចំនួនបានសម្តែងការព្រួយបារម្ភថា អ្នកប្តូរយេនឌ័រពីបុរសទៅជាស្ត្រី នៅតាមទីតាំងឃុំឃាំង

---

[42] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងស្ថាប័នផ្សេងទៀត របាយការណ៍រួមដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស កថាខណ្ឌ ៤៥។

[43] A/75/258 កថាខណ្ឌ ២៨។

[44] Taylor Nelson Sofres កម្ពុជា និងសហគមន៍ឥន្ទធនូកម្ពុជា *ទស្សនៈយល់ឃើញ ឥរិយាបទ និងអាកប្បកិរិយាចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា* (ឆ្នាំ២០១៥) *ទំព័រ ៨៤។*

[45] សហគមន៍ឥន្ទធនូកម្ពុជា “អំពើហិង្សាក្នុងគ្រួសារចំពោះស្ត្រីស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរយេនឌ័រ (LBT) នៅកម្ពុជា” ទំព័រ ៣ និងទំព័រ ៩។

ពុំមានលទ្ធភាពទទួលបានការថែទាំសុខភាពត្រឹមត្រូវក្នុងពេលជាប់ឃុំ រួមទាំងការព្យាបាលដោយអរម៉ូន និងការទៅពិនិត្យសុខភាពជាប្រចាំបន្ទាប់ពីការវះកាត់បញ្ជាក់យេនឌ័រ ដែលបានធ្វើឡើងកាលពីប្រាំមួយខែមុនពេលជាប់ឃុំ[46]។

៦២. អ្នកជំនាញឯករាជ្យព្រួយបារម្ភពីអវត្តមាននៃពិធីសារ និងគោលនយោបាយជាក់លាក់សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅទីតាំងឃុំឃាំង និងអំពីកង្វះទិន្នន័យទាក់ទងនឹងបុគ្គលទាំងនេះ។ ខណៈដែលក្រសួងមហាផ្ទៃអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញចន្លោះប្រហោងទាំងនេះ យន្តការបង្ការថ្នាក់ជាតិ អនុលោមតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប ក៏គួរបញ្ចូលខ្លឹមសារពាក់ព័ន្ធមួយចំនួនក្នុងវិធីសាស្ត្រ នៅពេលធ្វើទស្សនកិច្ចផងដែរ។

៦៣. លើសពីនេះ អ្នកជំនាញឯករាជ្យកត់សម្គាល់ថា គោលនយោបាយទាក់ទងនឹងការការពារអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ គួរត្រូវបានអនុវត្តគ្រប់ទីកន្លែងដកហូតសេរីភាព រួមមានជាអាទិ៍ ពន្ធនាគារ ក៏ដូចជាមណ្ឌលស្តារនីតិសម្បទា មណ្ឌលថែទាំជនវិបល្លាសស្មារតី និងកន្លែងផ្សេងទៀតដែលដកហូតសេរីភាពដើរហើរ និងទីតាំងជាក់ស្តែងផ្សេងទៀតដែលមានការដកហូតសេរីភាព។

## V. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

### ក. សេចក្តីសន្និដ្ឋាន

៦៤. ទោះបីជាមានការការពារការរើសអើង ដោយយោងតាមវេជ្ជមន្តនុញ្ញ រួមទាំងផ្អែកលើមូលដ្ឋានភេទ តាមលក្ខខណ្ឌកំណត់ដ៏តឹងរឹង ការមិនរាប់បញ្ចូលមូលដ្ឋាននៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ និងអត្ថិភាពដ៏តិចតួចនៃបទប្បញ្ញត្តិស្តីពីការមិនរើសអើង អាចនាំឱ្យមានការបកស្រាយតាមន័យត្រង់ ដែលពុំបានផ្តល់កិច្ចការពារបុគ្គលពីការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

៦៥. ក្នុងការជួបសន្ទនាជាមួយអ្នកជំនាញឯករាជ្យ តំណាងរាជរដ្ឋាភិបាលជាច្រើនបានប្រកាន់នូវទស្សនៈថាកត្តាដំបូងនៃការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នាគឺ "ការរើសអើងខ្លួនឯង" ពោលសំដៅដល់ការសម្រេចចិត្តលាក់បាំងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់មនុស្សម្នាក់ ដោយការភ័យខ្លាចថាមានការបដិសេធមិនទទួលស្គាល់ ការយាយី ឬរើសអើង។ អ្នកជំនាញឯករាជ្យក៏ព្យាយាមផ្តល់ការបំភ្លឺថា គ្មាននរណាម្នាក់ត្រូវបានបង្ខំឱ្យបង្ហាញនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេនោះឡើយ ទោះក្នុងកាលៈទេសៈណាក៏ដោយ។ ការសម្រេចចិត្តលាក់បាំង ជាជម្រើសផ្ទាល់ខ្លួនរបស់បុគ្គលសុទ្ធសាធ ពុំមែនជាកត្តានៃការរើសអើងនោះឡើយ។ តាមពិត ករណីនេះ បង្ហាញអំពីការភ័យខ្លាចពីការទទួលរងនូវទម្រង់នៃអំពើហិង្សា និងការរើសអើងដូចបានរៀបរាប់ខាងលើ។

៦៦. សមាជិកនៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា អង្គការសង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្ស តំណាងសំឡេងដែលមិនអាចខ្វះបានក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃគោល

[46] សូមមើលលិខិតឆ្លើយឆ្លងលេខ KHM ២/២០២០។

នយោបាយសាធារណៈល្អៗ។ នេះដោយសារតែហេតុផលជាច្រើន ក្នុងនោះ ពួកគេបានដឹងតថភាពជាក់ស្តែង និងទទួលបានការទុកចិត្តពីសហគមន៍ ពួកគេធ្វើការជាច្រើនទសវត្សរ៍មកហើយក្នុងការផ្តល់សេវាឯកទេស និងដោយឡែក និងបានបង្កើតទីតាំងសុវត្ថិភាពដែលអ្នកស្រឡាញ់ភេទដូចគ្នា បង្កើត និងរក្សាសហគមន៍។ អ្នកជំនាញឯករាជ្យផ្តល់យោបល់យ៉ាងមុតមាំឱ្យរាជរដ្ឋាភិបាលបណ្តុះ និងបង្កើនលំហសេរីភាព បើកឱ្យមានកិច្ចសន្ទនាជាមួយសង្គមស៊ីវិល ផ្អែកលើគំរូឧត្តមានុវត្តន៍ អនុវត្តដោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

៦៧. របៀបវារៈសម្រាប់ការតាមដានគួរអនុវត្តតាមការប្តេជ្ញាចិត្តសំខាន់ៗចំនួនបី ដែលបច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា កំពុងពិចារណាចាប់តាំងពីទទួលយកអនុសាសន៍ នៅក្នុងរបាយការណ៍ពិនិត្យជាសាកលតាមកាលកំណត់ កាលពីឆ្នាំ២០១៩ ៖ ការទទួលស្គាល់គ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា តាមរយៈការទទួលស្គាល់ស្របច្បាប់ចំពោះអាពាហ៍ពិពាហ៍ភេទដូចគ្នា ការទទួលស្គាល់តាមផ្លូវច្បាប់នៃអត្តសញ្ញាណយេនឌ័រ និងការអនុម័តច្បាប់ប្រឆាំងការរើសអើងគ្រប់ជ្រុងជ្រោយ។

៦៨. ជាពិសេស កង្វះការទទួលស្គាល់ស្របច្បាប់នៃអាពាហ៍ពិពាហ៍ភេទដូចគ្នា នៅតែជាឧបសគ្គចម្បងចំពោះការរួមបញ្ចូលក្នុងសង្គម។ អ្នកប្តូរយេនឌ័រពីស្ត្រីទៅជាបុរស មួយរូបមកពីខេត្តពោធិ៍សាត់បានលើកឡើងក្នុងអំឡុងពេលទស្សនកិច្ចថា ៖ «យើងរស់នៅដោយសុខសាន្ត ប៉ុន្តែមិនមានសុភមង្គលពេញលេញនោះទេ»។ អ្នកជំនាញឯករាជ្យបានទទួលសក្ខីកម្មរាប់សិបដែលរៀបរាប់អំពីឧបសគ្គ និងកង្វះការទទួលស្គាល់ស្របច្បាប់ចំពោះគ្រួសារផេន្នធន្ទទាំងក្នុងសេវាថែទាំសុខភាព ការទទួលមរតក និងកំណត់ត្រាស្មុំកូន ដែលបង្ហាញអំពីភាពជាឪពុកម្តាយដោយស្មើភាព។ សក្ខីកម្មទាំងនេះបានបង្ហាញអំពីសារសំខាន់ដ៏ធំធេងដែលពលរដ្ឋកម្ពុជាប្រកាន់ខ្ជាប់នឹងច្បាប់ ហើយការទទួលស្គាល់ជាអាពាហ៍ពិពាហ៍ស្របច្បាប់ នឹងជាគន្លឹះសំដៅជានាបានអត្ថប្រយោជន៍ជាច្រើននៃការដាក់បញ្ចូលក្នុងសង្គម។

៦៩. ក្នុងចំណោមការរៀបរាប់ជាច្រើនដ៏គួរឱ្យរំភើបចិត្ត ដែលអ្នកជំនាញឯករាជ្យបានស្តាប់ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចនៅកម្ពុជា មានការរៀបរាប់មួយរបស់អ្នកប្តូរយេនឌ័រពីស្ត្រីទៅជាបុរស អាយុ ៧២ឆ្នាំ មកពីខេត្ត។ ចាប់តាំងពីឆ្នាំ១៩៧៣ នៅពេល ពួកគេបានជួបគ្នាដំបូង គាត់ និងប្រពន្ធគាត់បានឆ្លងកាត់ការបំបែកបំបាក់ និងការជួបជុំគ្នាជាច្រើនលើកជាច្រើនសារ ដោយសារឪពុកម្តាយ គ្រួសារ សហគមន៍ និងអាជ្ញាធររដ្ឋ មានការយល់ខុស និងការរើសអើង។ ប៉ុន្តែ ក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ ពួកគេបានរស់នៅជាមួយគ្នាក្នុងផ្ទះដែលពួកគេបានសាងសង់លើដីតូចមួយ សម្រាប់ការដាំដុះ និងផ្គត់ផ្គង់ជីវិត។ ការរៀបរាប់របស់ពួកគេបានចងភ្ជាប់ប្រវត្តិសាស្រ្តខ្មែរ និងចំណាងភាពស្និទ្ធស្នាល នឹងជំនឿដ៏មុតមាំ ដែលគាត់បានរៀបរាប់ថា ៖ "យើងដឹងច្បាស់ក្នុងចិត្តថា យើងសុខចិត្តស្លាប់ល្អជាង ប្រសិនបើយើងមិនបានស្រឡាញ់គ្នា"។ ក្នុងសៀវភៅគ្រួសារ ពួកគេទាំងពីរនាក់ត្រូវបានចុះឈ្មោះជាបងប្អូនស្រីនឹងគ្នា។ អ្នកជំនាញឯករាជ្យសង្ឃឹមថា របាយការណ៍ និងអនុសាសន៍នាពេលនេះ នឹងក្លាយជាធាតុបន្ថែមមួយទៀត ដើម្បីជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់គ្រួសារពួកគេ និងគ្រួសាររាប់ពាន់ទៀតដែលមានស្ថានភាពបែបនេះ ឱ្យបានស្របច្បាប់។

## ខ. អនុសាសន៍

៧០. យោងតាមសេចក្តីសន្និដ្ឋាន និងសេចក្តីសង្កេតក្នុងរបាយការណ៍បច្ចុប្បន្ន អ្នកជំនាញឯករាជ្យបានផ្តល់អនុសាសន៍ដូចខាងក្រោម។

៧១. ទាក់ទងនឹងកិច្ចសហប្រតិបត្តិការជាមួយយន្តការសិទ្ធិមនុស្សអន្តរជាតិ អ្នកជំនាញឯករាជ្យបានផ្តល់អនុសាសន៍ឱ្យអាជ្ញាធរកម្ពុជា ៖

(ក) ផ្តល់សច្ចាប័នលើលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិផ្សេងទៀត ដែលកម្ពុជាមិនទាន់ចូលជាភាគី រួមទាំងការទទួលយកនីតិវិធីបណ្តឹងបុគ្គល និងបន្តចូលរួមជាមួយយន្តការ និងដំណើរការសិទ្ធិមនុស្សអន្តរជាតិ។

(ខ) បង្កើតផែនការអនុវត្ត ការពិនិត្យជាសាកលតាមកាលកំណត់ ដោយកំណត់ពេលវេលាជាក់លាក់ និងចូលរួមក្នុងយន្តការពិគ្រោះយោបល់ប្រចាំឆ្នាំអំពីផែនការអនុវត្តដែលមានការចូលរួមពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។

(គ) អនុវត្តអនុសាសន៍ដែលរដ្ឋាភិបាលទទួលយក ក្នុងអំឡុងការពិនិត្យជាសាកលតាមកាលកំណត់លើកទីបី ទាក់ទងនឹងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងលក្ខណៈភេទ ឱ្យបានត្រឹមឆ្នាំ២០២៤ និងធានានូវភាពស៊ីសង្វាក់គ្នារវាងការប្តេជ្ញាចិត្តដែលបានធ្វើឡើងក្នុងយន្តការការពិនិត្យជាសាកលតាមកាលកំណត់ និងសេចក្តីថ្លែងការណ៍ផ្លូវការដែលបានធ្វើឡើងនៅកម្រិតជាតិ។

៧២. ចំពោះក្របខណ្ឌច្បាប់ អ្នកជំនាញឯករាជ្យផ្តល់អនុសាសន៍ឱ្យអាជ្ញាធរកម្ពុជា ៖

(ក) ទទួលស្គាល់គ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា តាមផ្លូវច្បាប់ដោយទទួលស្គាល់ស្ថានភាពស្របច្បាប់នៃអាពាហ៍ពិពាហ៍ភេទដូចគ្នា។ មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ គន្លឹះទី៧ នៃក្រមរដ្ឋប្បវេណី និងមាត្រា ៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ គួរធ្វើវិសោធនកម្មស្របតាមគោលដៅទាំងនេះ។ កំណែទម្រង់ច្បាប់គួរធ្វើឡើងដើម្បីធានាដៃគូភេទដូចគ្នាទទួលបានអត្ថប្រយោជន៍ពេញលេញពីសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងអាពាហ៍ពិពាហ៍ រួមទាំងការសុំកូន។

(ខ) អនុម័តច្បាប់ប្រឆាំងការរើសអើង និងវិធានការជាក់លាក់ផ្សេងទៀត ដើម្បីបញ្ចូលនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងច្បាប់ជាតិកម្ពុជា។ ច្បាប់ប្រឆាំងការរើសអើងគួរគ្របដណ្តប់ទាំងវិស័យរដ្ឋ និងឯកជន និងផ្តល់ការការពារក្នុងបរិបទសំខាន់ៗ ដូចជា ការងារ ការអប់រំ ការថែទាំសុខភាព លំនៅដ្ឋាន និងការផ្តល់ទំនិញ និងសេវាកម្ម។ ដើម្បីធានានូវប្រសិទ្ធភាព ក្របខណ្ឌប្រឆាំងការរើសអើង គួរដាក់ចេញវិធានការប្រកបដោយប្រសិទ្ធភាពក្នុងការស៊ើបអង្កេតការចោទប្រកាន់ពីការរំលោភបំពាន និងផ្តល់សំណងដល់ជនរងគ្រោះ និងធានាគណនេយ្យភាពចំពោះជនល្មើសដែលត្រូវបានចោទប្រកាន់[47]។ ច្បាប់ប្រឆាំងការរើសអើងអាចមានទម្រង់ផ្សេងៗគ្នា។ ការបញ្ចូលមូលដ្ឋានភេទ និងអត្តសញ្ញាណយេនឌ័រ ក្នុងរដ្ឋធម្មនុញ្ញនឹងជាការអនុវត្តដ៏ប្រសើរ ដូច្នេះកម្ពុជាអាចធ្វើវិសោធនកម្ម មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ដើម្បីបញ្ចូលមូលដ្ឋានទាំងនេះជាមូលដ្ឋានជាក់លាក់ក្នុងការហាមឃាត់ការរើសអើង។

(គ) អនុម័តច្បាប់ ដើម្បីឱ្យអ្នកប្តូរយេនឌ័រ និងអ្នកមានយេនឌ័រចម្រុះ អាចផ្លាស់ប្តូរ

[47] សូមមើល A/72/172។

អត្តសញ្ញាណ និងលក្ខខណ្ឌសម្គាល់យេនឌ័ររបស់ពួកគេដោយស្របច្បាប់។ ជាគោលការណ៍ ដំណើរការនៃការទទួលស្គាល់អត្តសញ្ញាណយេនឌ័រតាមផ្លូវច្បាប់ គួរផ្អែកលើការសម្រេចចិត្តរបស់អ្នកដាក់ពាក្យសុំដោយខ្លួនឯង គួរបង្កើតជាដំណើរការរដ្ឋបាលសាមញ្ញមួយ និងចៀសវាងពីការប្រើលក្ខខណ្ឌដែលអាចបង្កជាការបំពាន ទទួលស្គាល់អត្តសញ្ញាណដែលពុំអាចញែកដាច់ច្បាស់លាស់ និងអាចផ្តល់លទ្ធភាពដល់អនីតិជនដូចគ្នានេះដែរ[48]។

(ឃ) បន្ថែមមូលដ្ឋាននៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រទៅក្នុងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌ ក្នុងគោលបំណងដាក់ទោសចំពោះការញុះញង់ឱ្យមានការរើសអើង និងអំពើហិង្សាផ្អែកលើហេតុផលទាំងនោះ និងអនុម័តច្បាប់ប្រឆាំងនឹងពាក្យសំដីស្អប់ខ្ពើមដែលកំណត់ថា ការរើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រលាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ ជាស្ថានទម្ងន់នៅពេលផ្តន្ទាទោស។

(ង) បង្កើតច្បាប់ដើម្បីធានាថានឹងមានការស៊ើបអង្កេត បទល្មើសដោយសារភាពស្អប់ខ្ពើមចំពោះអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ពីរភេទ និងអ្នកប្តូរយេនឌ័រ ប្រកបដោយប្រសិទ្ធភាព ព្រមទាំងកំណត់បទល្មើស និងផ្តន្ទាទោសឱ្យបានត្រឹមត្រូវ ហើយបុគ្គលដែលត្រូវបានរកឃើញថាមានពិរុទ្ធភាព ត្រូវផ្តន្ទាទោសឱ្យស័ក្តិសមទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើស ក៏ដូចជាផ្តល់សំណងដល់ជនរងគ្រោះប្រកបដោយប្រសិទ្ធភាព។

៧៣. ទាក់ទងនឹងក្របខណ្ឌស្ថាប័ន និងគោលនយោបាយ អ្នកជំនាញឯករាជ្យបានផ្តល់អនុសាសន៍ឱ្យអាជ្ញាធរកម្ពុជា ៖

(ក) បង្កើតស្ថាប័នជាតិសិទ្ធិមនុស្សឯករាជ្យមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។

(ខ) បញ្ជ្រាបការបញ្ចូលការការពារប្រឆាំងនឹងអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងគោលនយោបាយ និងផែនការសកម្មភាពនានារបស់ស្ថាប័នសំខាន់ៗ ដែលមានតួនាទីលើកកម្ពស់ការរួមបញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នាក្នុងសង្គម ដោយមានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល អង្គការសហប្រជាជាតិ និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

(គ) ធានាថាការការពារអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រត្រូវបានបញ្ចូលយ៉ាងពេញលេញក្នុងគោលនយោបាយ និងផែនការសកម្មភាពជាតិស្តីពីសិទ្ធិមនុស្សទាំងអស់ ក៏ដូចជាយន្តការនៃការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពទាំងអស់នេះ។

៧៤. ចំពោះការប្រមូល និងការគ្រប់គ្រងទិន្នន័យ ៖

(ក) អ្នកជំនាញឯករាជ្យបានផ្តល់អនុសាសន៍ឱ្យអាជ្ញាធរកម្ពុជា ពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងសហគមន៍ដែលរងផលប៉ះពាល់ ដើម្បីបង្កើតវិធីសាស្ត្រ និងពិធីសារស្តីពីការប្រមូល និងប្រើប្រាស់ទិន្នន័យទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងគោលបំណងឱ្យមានការមើលឃើញ និងយល់ដឹងអំពីធម្មជាតិ និងវិសាលភាពនៃការរើសអើង និងអំពើហិង្សាចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ដើម្បីផ្តល់ជាធាតុចូលសម្រាប់ការ

[48] សូមមើល A/73/152។

រៀបចំគោលនយោបាយសាធារណៈ។ ដើម្បីធ្វើដូច្នេះបាន អាជ្ញាធររដ្ឋគួរប្រកាន់យកវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សក្នុងការប្រមូល និងប្រើប្រាស់ទិន្នន័យ ហើយគិតគូរអំពីសិទ្ធិបុគ្គលក្នុងការកំណត់អត្តសញ្ញាណដោយសាមីខ្លួន ទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ការចូលរួមរបស់សហគមន៍ពាក់ព័ន្ធ ភាពឯកជនរបស់បុគ្គលដែលបានចូលរួមក្នុងកិច្ចប្រឹងប្រែងដើម្បីប្រមូលទិន្នន័យ ភាពសម្ងាត់នៃព័ត៌មានដែលទទួលបាន តម្លាភាព និងគណនេយ្យភាព[49]។

(ខ) អ្នកជំនាញឯករាជ្យបានផ្តល់អនុសាសន៍ ឱ្យអាជ្ញាធរកម្ពុជាបង្កើតយន្តការប្រមូលទិន្នន័យរយៈពេលខ្លី មធ្យម និងរយៈពេលវែង ក្នុងគោលបំណងបង្ហាញលម្អិត និងអនុវត្តច្បាប់ និងគោលនយោបាយការពារអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ ឧត្តមានុវត្តន៍អន្តរជាតិតែងតែរួមបញ្ចូលចំណុចទាំង៥ ខាងក្រោម ពេលចាប់ផ្តើមគិតគូរបញ្ហាទាំងនេះ ៖ សុខភាព ការអប់រំ សុខុមាលភាពសេដ្ឋកិច្ច សន្តិសុខផ្ទាល់ខ្លួន និងសេរីភាពចាកផុតពីអំពើហិង្សា និងការចូលរួមពលរដ្ឋ និងនយោបាយ។ រដ្ឋាភិបាលក៏គួរពិចារណាបញ្ចូលការប្រមូលទិន្នន័យស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងជំរឿនថ្នាក់ជាតិ។

(គ) ទិន្នន័យស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ គួរត្រូវបានបែងចែកតាមអាយុ ភេទ និងលក្ខណៈសេដ្ឋកិច្ចសង្គមពាក់ព័ន្ធ ដែលមានភាពចាំបាច់សម្រាប់ការបង្កើតគោលនយោបាយរដ្ឋប្រកបដោយប្រសិទ្ធភាព ដូចជា ស្ថានភាពសេដ្ឋកិច្ច ពិការភាព ពូជសាសន៍ ស្ថានភាពជនជាតិដើមភាគតិច និងស្ថានភាពនៃការធ្វើចំណាកស្រុកជាដើម។ អ្វីដែលចាំបាច់គឺត្រូវកំណត់ទិដ្ឋភាពជាច្រើនជ្រុង និងភាពប្រសព្វគ្នា ដើម្បីធ្វើផែនការ អនុវត្ត ត្រួតពិនិត្យ និងរាយការណ៍ឱ្យបានត្រឹមត្រូវ។

(ឃ) អ្នកជំនាញឯករាជ្យក៏បានផ្តល់អនុសាសន៍ ឱ្យរដ្ឋាភិបាលទទួលស្គាល់តួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការប្រមូល និងគ្រប់គ្រងទិន្នន័យអំពើហិង្សា និងការរើសអើងផ្អែកលើមូលហេតុនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ និងការផ្តល់ភស្តុតាងដែលអាចប្រើសម្រាប់បង្កើតគោលនយោបាយរដ្ឋ[50]។

៧៥. ចំពោះការការពារអំពើហិង្សា និងការបដិសេធក្នុងគ្រួសារ អ្នកជំនាញឯករាជ្យបានផ្តល់អនុសាសន៍ឱ្យអាជ្ញាធរកម្ពុជា ៖

(ក) បង្កើតប្រព័ន្ធដែលមានប្រសិទ្ធភាពសម្រាប់ការកត់ត្រា និងរាយការណ៍អំពីបទល្មើសដោយសារភាពស្អប់ខ្ពើម ផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

(ខ) រៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស និងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រសម្រាប់មន្ត្រីរដ្ឋាភិបាល ក្នុងគ្រប់សមាសធាតុនៃខ្សែសង្វាក់យុត្តិធម៌ រួមមាននគរបាល ព្រះរាជអាជ្ញា តុលាការ និងពន្ធនាគារ។ យន្តការរាយការណ៍ត្រឹមត្រូវគួរតែបង្កើតសម្រាប់ជនរងគ្រោះនៃអំពើហិង្សាពីសំណាក់មន្ត្រីនគរបាល ដោយហេតុផលនៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ជាក់ស្តែង ឬត្រូវបានសន្មត ក៏ដូចជាការជានាថា ការចោទ

[49] សូមមើល A/HRC/41/45។

[50] A/HRC/41/45, កថាខណ្ឌ ៧៧ និង ៨២។

ប្រកាន់ទាំងអស់ ត្រូវបានស៊ើបអង្កេតឱ្យសមស្រប ជនល្មើសដែលត្រូវបានចោទប្រកាន់ត្រូវទទួលខុសត្រូវ ចំណែកជនរងគ្រោះ ត្រូវមានសិទ្ធិទទួលបានសំណង។

(គ) អនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹងក្នុងចំណោមឪពុកម្ដាយ ក្រុមគ្រួសារ និងសហគមន៍ស្ដីពីភាពចម្រុះនៃភេទ និងយេនឌ័រ សំដៅកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារទៅលើអ្នកស្រឡាញ់ភេទដូចគ្នា និងការបដិសេធដោយសមាជិកគ្រួសារ។

(ឃ) ធ្វើការសិក្សាអំពីការអនុវត្តការកែប្រែបែបបង្ខំ រួមទាំងដោយសមាជិកគ្រួសារ អ្នកដឹកនាំសាសនា និងគ្រូថ្នាំបុរាណ ព្រមទាំងបង្កើតច្បាប់ គោលនយោបាយ និងគោលការណ៍ណែនាំពាក់ព័ន្ធ ដើម្បីធានាថា កុមារ និងមនុស្សពេញវ័យទទួលបានកិច្ចការពារ ចាកផុតពីការអនុវត្តបែបនេះ។ រដ្ឋគួរជំរុញឱ្យមានកិច្ចសន្ទនាជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមទាំងអង្គការជំនាញផ្នែកវេជ្ជសាស្រ្ត និងសុខភាព អង្គការសាសនា ស្ថាប័នអប់រំ និងអង្គការសហគមន៍មូលដ្ឋាន ដើម្បីលើកកម្ពស់ការយល់ដឹងពីការរំលោភសិទ្ធិមនុស្សទាក់ទងនឹងការអនុវត្តការកែប្រែបែបបង្ខំ[51]។

៧៦. ចំពោះការអប់រំ អ្នកជំនាញឯករាជ្យបានផ្ដល់អនុសាសន៍ឱ្យអាជ្ញាធរកម្ពុជា ៖

(ក) អនុវត្តកម្មវិធីសិក្សាអប់រំសុខភាពថ្មី ដោយរួមបញ្ចូលនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ នៅគ្រប់កម្រិត នៅទូទាំងប្រទេស។ រាជរដ្ឋាភិបាលគួរធានាដាក់បញ្ចូលនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងឯកសារពាក់ព័ន្ធទាំងអស់ រួមទាំងការបណ្ដុះបណ្ដាលគ្រូបង្រៀន និងក្នុងសៀវភៅសិក្សាគោលរបស់សិស្ស។

(ខ) អនុម័តគោលនយោបាយ និងគោលការណ៍ណែនាំ ដើម្បីធានាថា សិស្សានុសិស្សកម្ពុជាអាចបង្ហាញយេនឌ័រដោយសេរីនៅតាមសាលារៀន រួមទាំងការលុបចោលវិន័យស្លៀកពាក់ និងការកាត់សក់ ចេញពីលក្ខខណ្ឌឯកសណ្ឋានសាលារៀន ហើយធានាថា សាលារៀនមិនបន្តហាមឃាត់ និងគាបសង្កត់លើការបង្ហាញយេនឌ័រចម្រុះក្នុងចំណោមសិស្សានុសិស្ស។

៧៧. ចំពោះការងារ និងកិច្ចការពារសង្គម អ្នកជំនាញឯករាជ្យបានផ្ដល់អនុសាសន៍ឱ្យអាជ្ញាធរកម្ពុជា ៖

(ក) ធ្វើការស្ទង់មតិ និងសិក្សាអំពីស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នានៅកន្លែងធ្វើការដើម្បីកំណត់ឱ្យឃើញឧបសគ្គ និងបញ្ហាប្រឈមដែលពួកគេកំពុងតែជួបប្រទះក្នុងបរិបទ ការងារ និងកិច្ចគាំពារសង្គម ព្រមទាំងបង្កើតគោលនយោបាយ និងគោលការណ៍ណែនាំ ពាក់ព័ន្ធដើម្បីធានានូវកិច្ចការពារពីអំពើហិង្សា និងការរើសអើងនៅកន្លែងធ្វើការ និងក្នុងការផ្ដល់សេវាកិច្ចគាំពារសង្គម។

(ខ) ធានាលទ្ធភាពទទួលបានយុត្តិធម៌ និងយន្តការរាយការណ៍សម្រាប់ជនរងគ្រោះនៃការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងបរិបទការងារ និងរៀបចំយុទ្ធនាការផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាលស្ដីពីការមិនអត់ឱន ចំពោះការរើសអើងផ្អែកលើមូលហេតុនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

(គ) រួមបញ្ចូលនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងគោលនយោបាយ និង

[51] សូមមើល A/HRC/44/53

ផែនការសកម្មភាពនានា សំដៅប្រយុទ្ធប្រឆាំងភាពក្រីក្រ និងភាពក្រីក្រខ្លាំងនៅកម្ពុជា។

៧៨. ចំពោះសិទ្ធិទទួលបានសេវាសុខាភិបាល និងការទទួលបានការថែទាំសុខភាព អ្នកជំនាញឯករាជ្យបានផ្តល់អនុសាសន៍ឱ្យអាជ្ញាធរកម្ពុជា ៖

(ក) ស្រាវជ្រាវដើម្បីកំណត់វិសមភាពសុខភាព និងស្ថានភាពសុខភាពរបស់អ្នកមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះ ក្នុងគោលបំណងរួមបញ្ចូលតម្រូវការសុខភាពជាក់លាក់របស់ពួកគេក្នុងគោលនយោបាយសុខភាពសាធារណៈ។

(ខ) បង្កើតកម្មវិធីបណ្តុះបណ្តាល និងយុទ្ធនាការលើកកម្ពស់ការយល់ដឹងសម្រាប់អ្នកផ្តល់សេវាវេជ្ជសាស្ត្រ ក្នុងគោលបំណងប្រយុទ្ធប្រឆាំងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងប្រព័ន្ធសុខាភិបាល និងដើម្បីធានាការទទួលបានសេវាថែទាំសុខភាពដែលមានគុណភាពខ្ពស់ គ្មានការមាក់ងាយ សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា។

(គ) ធានាលទ្ធភាពទទួលបានការថែទាំសុខភាព ទាក់ទងនឹងការបញ្ជាក់យេនឌ័រ ក្នុងតម្លៃសមរម្យសម្រាប់អ្នកប្តូរយេនឌ័រ និងអ្នកមានយេនឌ័រចម្រុះ ដែលរួមទាំងការព្យាបាលដោយអរម៉ូន ការវះកាត់ ឬសេវាថែទាំសុខភាពផ្សេងទៀត ដើម្បីឱ្យរាងកាយរបស់ពួកគេសមស្រប និងក្នុងកម្រិតមួយដែលអាចធ្វើទៅបាន ស្របតាមយេនឌ័រដែលបុគ្គលម្នាក់ៗចង់បាន។

(ឃ) ធានាថាបុគ្គលដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះ អាចទទួលបានការគាំទ្រ និងការព្យាបាលផ្លូវចិត្តជាក់លាក់ស្របតាមតម្រូវការរបស់ពួកគេ និងផ្តល់ដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្រដែលបានទទួលការបណ្តុះបណ្តាល។

(ង) បន្ត និងពង្រីកកិច្ចខិតខំប្រឹងប្រែង ដើម្បីអាចឱ្យក្រុមប្រជាជនសំខាន់ៗ ទទួលបានសេវាសុខភាពទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងផ្តល់ការថែទាំជាក់លាក់ និងងាយស្រួលសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ក៏ដូចជាបង្កើតផែនការសកម្មភាពស្តីពីការអនុវត្តភាពជាដៃគូសាកលសម្រាប់សកម្មភាពលុបបំបាត់រាល់ទម្រង់នៃការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍ ដែលរួមបញ្ចូលតម្រូវការ និងកង្វល់របស់បុគ្គលដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះ រួមទាំងសកម្មភាពជាក់លាក់ដើម្បីប្រយុទ្ធប្រឆាំងការប្រកាន់ទស្សនៈជាប្រព័ន្ធចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ដែលមានមេរោគអេដស៍/ជំងឺអេដស៍។

៧៩. ចំពោះទីតាំងឃុំឃាំង អ្នកជំនាញឯករាជ្យបានផ្តល់អនុសាសន៍ឱ្យអាជ្ញាធរកម្ពុជា ៖

(ក) ធ្វើការសិក្សាអំពីស្ថានភាពសិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នា នៅទីតាំងឃុំឃាំង និងបង្កើតគោលនយោបាយ និងគោលការណ៍ណែនាំពាក់ព័ន្ធស្តីពីការព្យាបាល ក្នុងពេលឃុំឃាំង ដែលគិតគូរអំពីតម្រូវការ និងស្ថានភាពងាយរងគ្រោះរបស់ពួកគេផ្អែកលើគោលការណ៍ណែនាំដែលមានស្រាប់ និងឧត្តមានុវត្តន៍[52]។

(ខ) បញ្ចូលសមាសធាតុជាក់លាក់ទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ

[52] សូមមើលសមាគមដើម្បីការបង្ការទប់ស្កាត់ទារុណកម្ម *ឆ្ពោះទៅរកការការពារអ្នកស្រឡាញ់ភេទដូចគ្នាដែលត្រូវបានដកហូតសេរីភាព៖ មគ្គុទេសក៍ស្តីពីការតាមដាន* (ឆ្នាំ២០១៨)។

ក្នុងវិធីសាស្ត្រសម្រាប់ទស្សនកិច្ច និងការរាយការណ៍របស់យន្តការបង្ការថ្នាក់ជាតិ ក្រោមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។